ក

មាតិកា

I- ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៣-៥-២០០២	-ព្រះរាជក្រឹត្យ នស/រកត/០៥០២/១១១ ស្តីពីការតែងតាំងលោកជំទាវ **គង់ ហាច** ជាឧបការីប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា	១១២០
១០-៥-២០០២	-ព្រះរាជក្រឹត្យ នស/រកត/០៥០២/១១៩ ស្តីពីការតែងតាំងឯកឧត្តម **ហ៊ាង ហ្វូខាយ** ជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា	១១២១
១១-៥-២០០២	-ព្រះរាជក្រឹត្យ នស/រកត/០៥០២/១២០ស្តីពីការតម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈចំពោះសពលោកវរសេនីយ៍ឯក **ម៉ុល ទាន់ម៉ុន**	១១២២
១១-៥-២០០២	-ព្រះរាជក្រឹត្យ នស/រកត/០៥០២/១២១ ស្តីពីការតែងតាំងលោកឧត្តមសេនីយ៍ត្រី **សួស អន្លារ៉** ជា ឧកញ៉ា	១១២៣

II- រាជរដ្ឋាភិបាល

អនុក្រឹត្យ

០៩-៤-២០០២	-អនុក្រឹត្យលេខ ២៩ អនក្រ.បក ស្តីពីបទវិន័យទូទៅសំរាប់កងយោធពលខេមរភូមិន្ទ (ភ្ជាប់តារាងឧបសម្ព័ន្ធ)	១១២៤
១៣-៥-២០០២	-អនុក្រឹត្យលេខ ៤០ អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃក្រសួងមហាផ្ទៃ	១២០១
១៣-៥-២០០២	-អនុក្រឹត្យលេខ ៤១ អនក្រ.បក ស្តីពីការរៀបចំកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងមហាផ្ទៃ	១២០៤
០៩-៥-២០០២	-អនុក្រឹត្យលេខ ២២៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១២០៨
១០-៥-២០០២	-អនុក្រឹត្យលេខ ២២៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ	១២០៩
១០-៥-២០០២	-អនុក្រឹត្យលេខ ២២៧ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា	១២១១
១០-៥-២០០២	-អនុក្រឹត្យលេខ ២២៨ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ចនិងតែងតាំងនាយនគរបាលជាតិជាន់ខ្ពស់	១២១២
១៣-៥-២០០២	-អនុក្រឹត្យលេខ ២២៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	១២១៤
១៤-៥-២០០២	-អនុក្រឹត្យលេខ ២៣០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១២១៥
១៥-៥-២០០២	-អនុក្រឹត្យលេខ ២៣១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១២១៦

ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១១១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៣០៣ រស ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០២

ត្រាស់បង្គាប់

មាត្រា១ .- តែងតាំងលោកជំទាវ គង់ ចាច ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា២ .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

ពរល-០៥-០៥-០០១២១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០០២

លេខៈ ១០៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១១៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ម៉ាង ហ្វូឡាយ** ជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

៣៧ល.០២.០៥.០០១២៩

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០២

លេខៈ ១១១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០០២
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាន់ តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១២០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: តម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈចំពោះសពលោកវរៈសេនីយ៍ឯក ម៉ុល ទ៉ាន់ថុន អត្តលេខ ០២២៣ អនុប្រធាននាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២: នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

៣រល.០៤.០៥.០០១៣០

លេខ: ១៧០ ច.ល

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០២

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១២១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោកឧត្តមសេនីយ៍ត្រី សួស អង្គារ៉

ជា

ឧភញ៉ា

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ:១០៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

[signature]

[illegible] តាន់

៣រល-០២.០៥.០០១៣១

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

បទវិន័យទូទៅសំរាប់ កងយោធពលខេមរភូមិន្ទ

+++++

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពី លក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០១

សំរេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ កំណត់បទវិន័យទូទៅ សំរាប់កងយោធពលខេមរភូមិន្ទនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ២.-

អនុក្រឹត្យនេះមានវិសាលភាព អនុវត្តចំពោះកងយោធពលខេមរភូមិន្ទ គ្រប់ប្រភេទ គ្រប់ឋានានុក្រម និងគ្រប់លំដាប់ឋានន្តរស័ក្តិ ។

កងយោធពលខេមរភូមិន្ទ ត្រូវមានភក្តីភាពចំពោះ ជាតិ សាសនា ព្រះមហាក្សត្រ និងបំពេញការងារទៅតាមឋានានុក្រម ។

ជំពូកទី ២
ឋានានុក្រម និង បញ្ជា

មាត្រា ៣.-

ឋានានុក្រមនៃកងយោធពលខេមរភូមិន្ទ ត្រូវផ្អែកលើមូលដ្ឋាននៃរចនាសម្ព័ន្ធដែលបានកំណត់នូវមុខនាទីនីមួយៗ និងភារកិច្ចទទួលខុសត្រូវរបស់ខ្លួន តាមលំដាប់ឋានន្តរស័ក្តិ ។

ឋានានុក្រមរបស់កងយោធពលខេមរភូមិន្ទមានដូចតទៅ :

- ពលទាហាន
- នាយទាហានរង
- នាយទាហាន

យោធិនគ្រប់រូប ក្នុងកិច្ចបំពេញការងាររបស់ខ្លួន ត្រូវចំណុះគ្នាពីមួយទៅមួយតាមលំដាប់ឋានានុក្រម លើកលែង តែមានច្បាប់ដោយឡែកពីនេះ ដាក់អោយប្រើប្រាស់ជាធរមាន ។

ការគោរពតាមលំដាប់នៃឋានានុក្រម មានដូចខាងក្រោម :

- ក្នុងករណីឋានន្តរស័ក្តិស្មើគ្នា ត្រូវគិតពីអតីតភាពនៃឋានន្តរស័ក្តិ
- ក្នុងករណីអតីតភាពនៃឋានន្តរស័ក្តិស្មើគ្នាទៀត ត្រូវគិតពីអតីតភាពនៃឋានន្តរស័ក្តិមុន ។

មាត្រា ៤.-

អ្នកដឹកនាំគ្រប់ជាន់ថ្នាក់មានសិទ្ធិគ្រប់គ្រាន់ ក្នុងការគ្រប់គ្រង ដឹកនាំ បញ្ជា សំរេចលើការងារ ក្នុងក្របខ័ណ្ឌ តួនាទី ភារកិច្ចរបស់ខ្លួន ។ យោធិនគ្រប់រូប ដែលបំពេញមុខងារក្នុងឋានៈជាបណ្តោះអាសន្ន ឬ ស្តីទី ដែលថ្នាក់ដឹកនាំ បានប្រគល់សិទ្ធិអោយមានសិទ្ធិអំណាច និង ការទទួលខុសត្រូវ ក្នុងមុខងាររបស់ខ្លួនដូចពេញសិទ្ធិដែរ ។

ឃ

អ្នកដឹកនាំគ្រប់ជាន់ថ្នាក់អាចប្រគល់អំណាច មួយចំនួនទៅអ្នកដែលស្ថិតនៅក្រោមបញ្ជារបស់ខ្លួន បានទៅតាមការកំណត់នៃបទបញ្ជារបស់កងយោធពលខេមរភូមិន្ទ។

មាត្រា ៥.-

បញ្ជារបស់អ្នកដឹកនាំគ្រប់ជាន់ថ្នាក់តំរូវអោយយោធិន ឬកងឯកភាពចំណុះទាំងឡាយអនុវត្តដោយផ្ទាល់ ដោយចំពោះ និងដោយពេញលេញ។

ក្នុងករណីអ្នកដឹកនាំនៃកងឯកភាពមួយមិនអាចបំពេញមុខងាររបស់ខ្លួនបាន ក្នុងស្ថានភាពណាមួយ ត្រូវចាត់តាំងអ្នកជំនួសដោយលាយលក្ខណ៍អក្សរ រហូតដល់ សាមីខ្លួនជាអ្នកដឹកនាំពេញសិទ្ធិ មកកាន់ដំណែងឡើងវិញ។ អវត្តមានរបស់អ្នកដឹកនាំពេញសិទ្ធិត្រូវចុះបញ្ជាក់ក្នុងសៀវភៅ រដ្ឋបាលទុកជាកំណត់-ហេតុ។

អ្នកដឹកនាំស្តីទី ត្រូវទទួលខុសត្រូវ ក្នុងការសំរេចអ្វីៗទាំងអស់ ក្នុងអង្គភាពរបស់ខ្លួន។

ជំពូកទី ៣
ករណីយកិច្ច និងការទទួលខុសត្រូវរបស់យោធិន

មាត្រា ៦.-

យោធិនគ្រប់រូប មានករណីយកិច្ចក្នុងនាមជានាយអោយបញ្ជាផង និងក្នុងនាមជាអ្នកក្រោមបង្គាប់ទទួលបញ្ជាផង។

ក្រៅពីករណីយកិច្ច និងការទទួលខុសត្រូវផ្ទាល់ ដោយឡែកយោធិនមានកាតព្វកិច្ចរួមដូចតទៅ :

១-ជាសមាជិកក្នុងកងទ័ព :

- គោរពបញ្ជា ដែលទទួលស្របតាមការកំណត់របស់ច្បាប់
- មានសេចក្តីទៀងត្រង់និងសេចក្តីថ្លៃថ្នូរប្រកបដោយកិត្តិយស
- ប្រតិបត្តិ តាមបទបញ្ជាយោធា ទោះបីជាសាមីខ្លួនយល់ថាបទបញ្ជានោះពិបាកប្រតិបត្តិតាមដោយប្រការណាមួយក៏ដោយ
- រក្សាការសំងាត់ និងរក្សាពាក្យសំងាត់ជាពិសេសអំពីកិច្ចការយោធា
- ថែទាំ សំភារៈ និង ថវិកាទ្រព្យសម្បត្តិផ្សេងៗ ...

២-នៅពេលបំពេញតួនាទីក្នុងកងឯកភាព :

-ខិតខំប្រតិបត្តិការងារ ដោយឥតសំចៃកម្លាំងគ្រប់ពេលវេលា

- ខំប្រឹងរៀនសូត្រ ដើម្បីអោយមានសមត្ថភាពក្នុងការបំពេញតួនាទី និង ដើម្បីចូលរួមលើកតំលៃ កងឯកភាពរបស់ខ្លួន

- ខំប្រឹងហ្វឹកហាត់ដើម្បីប្រសិទ្ធភាពការងារ

- និងត្រៀមកម្លាំងកាយ កម្លាំងចិត្តក្នុងការប្រយុទ្ធ។

មាត្រា ៧.-

ក្នុងឋានៈជានាយ យោធិនត្រូវ :

-មានការសំរេចក្នុងការអោយបញ្ជាដោយម៉ឺងម៉ាត់ និងច្បាស់លាស់ និងតាមដានរាល់ការអនុវត្តន៏បញ្ជាទាំងនោះ

-ទទួលខុសត្រូវចំពោះការអោយបញ្ជាទាំងឡាយ

-គោរពសិទ្ធិអ្នកនៅក្រោមបង្គាប់

-ផ្តល់ពត៌មានសម្ងាត់ ដល់អ្នកនៅក្រោមបង្គាប់ទាំងឡាយ ក្នុងករណីចាំបាច់

-ជូនរង្វាន់ដល់អ្នកមានស្នាដៃ ឬដាក់ទណ្ឌកម្មដល់អ្នកបានធ្វើខុសតាមកំរិតកំហុស នៅក្នុងក្របខ័ណ្ឌមុខងាររបស់ខ្លួន

-កត់សម្គាល់ និងអោយមូលវិចារណ៏ដល់យោធិននៅក្រោមបង្គាប់ ដែលបានបំរើ ឬបំពេញមុខងារជារៀងរាល់ឆ្នាំ ហើយក្រើនរំលឹកពីកំហុសរបស់យោធិនម្នាក់ៗ ដើម្បីអោយគេកែតម្រង់ខ្លួន

-យកចិត្តទុកដាក់ ពីជីវភាពរស់នៅផ្ទាល់របស់អ្នកនៅក្រោមបង្គាប់ ហើយត្រូវរាយការណ៏ទៅស្ថាប័នមានសមត្ថកិច្ចជួយដោះស្រាយ ក្នុងករណីចាំបាច់។

ក្នុងឋានៈជានាយអោយបញ្ជា យោធិនមិនអាចគេចផុតពីការទទួលខុសត្រូវក្នុងការអនុវត្តន៏បញ្ជាណាមួយដែលខ្លួនដាក់ចុះអោយថ្នាក់ក្រោមអនុវត្តនោះឡើយ។

បញ្ជាទាំងឡាយត្រូវតែបញ្ជូនទៅតាមឋានានុក្រម ។ក្នុងករណីបន្ទាន់អាចធ្វើទៅតាមផ្លូវកាត់បាន ប៉ុន្តែត្រូវជូនដំណឹងដល់ថ្នាក់កណ្តាលបន្តបន្ទាប់ដែលពាក់ព័ន្ធ អោយបានជ្រាបផងដែរ ។

មាត្រា ៨.-

ការគោរពបញ្ជា គឺជាករណីយកិច្ចចំបងរបស់អ្នកនៅក្រោមបង្គាប់ ។

ក្នុងឋានៈជាអ្នកនៅក្រោមបង្គាប់ យោធិនត្រូវៈ

-អនុវត្តដោយភក្ដីភាព នូវបញ្ជាដែលខ្លួនទទួល ហើយទទួលខុសត្រូវផ្ទាល់ចំពោះការអនុវត្តន៍បញ្ជានោះ

-មានគំនិតវាងវៃជានិច្ច ក្នុងការអនុវត្តន៍បញ្ជានៅគ្រប់កាលៈទេសៈ

រាយការណ៍ជាចាំបាច់ក្រោយពីអនុវត្តរួចនូវបញ្ជានីមួយៗ ។ ក្នុងករណីមិនអាចអនុវត្តបាននូវបញ្ជាដោយប្រការណាមួយត្រូវធ្វើសេចក្ដីរាយការណ៍ជាបន្ទាន់ជូនអ្នកអោយបញ្ជា ។

អ្នកក្រោមបង្គាប់មិនត្រូវអនុវត្តបញ្ជាដោយអាការៈបញ្ឆោះបញ្ឆៀកឬអនុវត្តបញ្ជាដែលមានលក្ខណៈផ្ទុយពីច្បាប់សង្គ្រាម ផ្ទុយពីអនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខា ។

អ្នកក្រោមបង្គាប់អនុវត្តមិនត្រឹមត្រូវតាមបញ្ជា ត្រូវទទួលទណ្ឌកម្មផ្នែកវិន័យ និងទទួលទោសតាមច្បាប់ ។

មាត្រា ៩.-

យោធិនត្រូវគោរព និងអនុវត្តរាល់បញ្ជាដោយមានស្មារតីទទួលខុសត្រូវ ។ បញ្ជាណាដែលមានភាពច្បាស់ក្រឡែតផ្ទុយពីច្បាប់ ឬផ្ទុយពីអនុសញ្ញាអន្តរជាតិត្រូវហាមឃាត់ ។ ក្នុងករណីនេះអ្នកបញ្ជាក្ដី អ្នកអនុវត្តក្ដី ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

យោធិន ដែលមិនអនុវត្តបញ្ជា ដែលខ្លួនយល់ថាមានភាពច្បាស់ក្រឡែតផ្ទុយពីច្បាប់ ឬអនុសញ្ញាអន្តរជាតិ ត្រូវទទួលទោសត្រឹមតែវិន័យយោធា ។ ផ្ទុយទៅវិញ បើខ្លួនអនុវត្តបញ្ជាខុសច្បាប់នោះ យោធិននឹងទទួលខុសត្រូវផ្ទាល់ខ្លួនទាំងផ្នែករដ្ឋប្បវេណី និងផ្នែកព្រហ្មទណ្ឌ ។

មាត្រា ១០.-

ក្នុងការប្រយុទ្ធ យោធិនត្រូវៈ

-មានសេចក្ដីក្លាហាន ហ៊ានប្រឈមមុខចំពោះគ្រោះថ្នាក់ និងហ៊ានធ្វើពលីកម្មគ្រប់បែបយ៉ាង ដើម្បីសំរេចនូវបេសកកម្ម ដែលខ្លួនទទួល

-រិះរកគ្រប់មធ្យោបាយដើម្បីអោយបានដល់គោលដៅកំណត់ទុក ឬកាន់កាប់ទីតាំងដែលខ្លួនបានទទួលបញ្ជា

-ប្រមូលថែរក្សានូវអាវុធយុទ្ធភ័ណ្ឌ និងសំភារៈទាំងឡាយរបស់មិត្តរួមអាវុធដែល ពលី របួស ឬមានជំងឺ

-ធ្វើយ៉ាងណាកុំអោយសត្រូវចាប់ខ្លួនបាន ខិតខំរកមធ្យោបាយទៅកាន់កងឯកភាព ឬអាជ្ញាធរដែនដី ដែលនៅជិតជាងគេបំផុត ក្នុងករណីមិនអាចប្រយុទ្ធបាន និងដាច់ទំនាក់ទំនង ។

ក្នុងកាលៈទេសៈណាក៏ដោយ យោធិនមិនត្រូវៈ

-បោះបង់អាវុធយុទ្ធភ័ណ្ឌ និងសំភារៈដែលនៅប្រើការកើត

-សំរុះសំរួលជាមួយសត្រូវ

-ប្រគល់ខ្លួនអោយសត្រូវ មុនពេលប្រយុទ្ធលែងកើត ឬអស់សំភារៈប្រយុទ្ធ

-ប្រព្រឹត្តល្មើសច្បាប់សង្គ្រាម ដែលមានចែងក្នុងសន្ធិសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា ។

មាត្រា ១១.-

យោធិនជាមេបញ្ជាការត្រូវ :

-ដឹកនាំការប្រយុទ្ធ និងបន្តការប្រយុទ្ធអោយបានសំរេច ឬដឹកនាំការប្រយុទ្ធរហូតដល់ដំណាក់កាលចុងក្រោយ

-ដាស់តឿន ឬលើកទឹកចិត្តក្នុងការប្រយុទ្ធគ្រប់កាលៈទេសៈ ឬក្នុងករណីចាំបាច់ អាចប្រើមធ្យោបាយបង្ខំទៀតផង

-ប្រើគ្រប់មធ្យោបាយ ដើម្បីការពារកុំអោយឯកសារសំខាន់ៗ ឬសំភារៈអាវុធយុទ្ធភ័ណ្ឌធ្លាក់ទៅក្នុងកណ្តាប់ដៃសត្រូវ

-ប្រមូលផ្តុំឡើងវិញនូវកងទ័ព កងឯកភាព ចំណុះបញ្ជាការផ្សេងៗពីគ្នា ដែលត្រូវកាត់ផ្តាច់ការគ្រប់គ្រងបញ្ជាដោយសត្រូវ ដាក់ក្រោមការដឹកនាំបញ្ជារបស់បញ្ជាការថ្មីណាម្នាក់ ដែលមានលំដាប់ឋានន្តរស័ក្តិខ្ពស់ជាងគេ ។

មាត្រា ១២.-

ក្នុងករណីមេបញ្ជាការ និងមេបញ្ជាការរងទាំងអស់ត្រូវពលី យោធិនដែលមានសមត្ថភាពខ្ពស់ និងក្លាហានជាងគេត្រូវឡើងបញ្ជា ហើយបន្តការប្រយុទ្ធតទៅទៀត ។

ក្នុងករណីធ្លាក់ជាឈ្លើយសឹក យោធិននៅតែស្ថិតជាយោធិនដដែល ។

ក្នុងករណីធ្លាក់ជាឈ្លើយសឹក យោធិនត្រូវរិះរកមធ្យោបាយរត់អោយរួចពីការឃុំឃាំង ដើម្បីរិះរក

4L

៦

វិធីប្រយុទ្ធតបតវិញ ។ក្នុងករណីរត់គេចខ្លួនមិនរួច ត្រូវតែប្ដេជ្ញាតស៊ូគ្រប់បែបយ៉ាងចំពោះការតាមសង្កត់របស់សត្រូវ ដោយមិនព្រមផ្ដល់ពត៌មានអោយសត្រូវ ហើយត្រូវមានសាមគ្គីភាពជាទិច្ច រវាងមិត្តរួមអាវុធ ព្រមទាំងជួយឧបត្ថម្ភចំពោះអ្នកដែលមានបំណងរត់គេចខ្លួន ទោះបីខ្លួនឯងពុំអាចរត់រួច ដោយហេតុអ្វី ឬរបួសក៏ដោយ ។

យោធិនដែលធ្លាក់ជាឈ្លើយសឹក ត្រូវប្រកាន់ខ្ជាប់នូវវិន័យ និង គោរពបញ្ជាពោកកាំនៅរួព្រមជាមួយ នឹងមិត្តរួមអាវុធរបស់ខ្លួន ដែលធ្លាក់ជាឈ្លើយសឹកដូចគ្នា ។

មាត្រា ១៣.-

ត្រូវហាមឃាត់ដល់យោធិននូវប្រការទាំងឡាយដូចខាងក្រោម :

-សម្លាប់ឈ្លើយសឹក

-បំផ្លាញ ឬប្លន់ទ្រព្យសម្បត្តិប្រជាពលរដ្ឋ

-ចាប់ចងមនុស្សយកទៅធ្វើជាថ្នូរ ដើម្បីផលប្រយោជន៍អ្វីមួយ

-ប្រើអំពើហិង្សាចំពោះប្រជាពលរដ្ឋ ក្នុងពេលដែលខ្លួនបានចូលទៅកាន់កាប់ទីកន្លែងប្រយុទ្ធណាមួយ

-ធ្វើទោសដល់បុគ្គលទាំងឡាយ ដោយគ្មានការវិនិច្ឆ័យពីតុលាការ

-រំលោភបំពានលើរាងកាយអ្នកជម្ងឺ អ្នករបួស អ្នកលង់ទឹក ឈ្លើយសឹក និងប្រជាពលរដ្ឋស៊ីវិល

-ធ្វើឃាត ឬធ្វើទារុណកម្មគ្រប់បែបយ៉ាង

-ឆែកឆេរយកទ្រព្យសម្បត្តិរបស់សាកសព ឬអ្នករបួស ។

មាត្រា ១៤.-

យោធិនត្រូវថែទាំឈ្លើយសឹកដែលចាប់បានតាមលក្ខណៈមនុស្សធម៌ និងគោរពសិទ្ធិក្នុងការថែរក្សាទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់គេ លើកលែងតែអាវុធយុទ្ធភ័ណ្ឌ ឬឯកសារយោធា ដែលចាំបាច់ត្រូវដកហូត ហើយបញ្ជូនឈ្លើយសឹកទៅកន្លែងប្រមូលផ្ដុំក្នុងរយៈពេលខ្លី ។

មាត្រា ១៥.-

យោធិនជាបុគ្គលិកសុខាភិបាលត្រូវ :

-ចូលរួមក្នុងសកម្មភាពប្រយុទ្ធជាមួយមិត្តរួមអាវុធ

-ជួយមិត្តរួមអាវុធដោយមធ្យោបាយបច្ចេកទេស ដែលខ្លួនមានក្នុងស្មារតីសាមគ្គី

-ទទួលព្យាបាលអ្នករបួស និងអ្នកជម្ងឺ ដោយគ្មានការរើសអើង ភេទ សញ្ជាតិ ពូជសាសន៍ សាសនា និងនិន្នាការផ្សេងៗ

-ត្រូវនៅប្រចាំការជិតអ្នករបួស ប្រសិនជាស្ថានភាពប្រយុទ្ធអនុគ្រោះ ។

ក្នុងករណីតំរូវអោយបោះបង់អ្នកជម្ងឺ ដោយហេតុផលជាចាំបាច់ក្នុងការប្រយុទ្ធ ត្រូវចុះក្នុងបញ្ជីអោយបានត្រឹមត្រូវ ។

ជំពូកទី ៤

សិទ្ធិរបស់យោធិន

មាត្រា ១៦.-

យោធិនគ្រប់រូបមានសិទ្ធិ និងសេរីភាពដូចប្រជាពលរដ្ឋដទៃទៀត ក៏ប៉ុន្តែត្រូវមានអព្យាក្រឹត្យភាពក្នុងការបំពេញមុខនាទីស្របតាមច្បាប់ស្តីពី លក្ខន្តិកៈទូទៅ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

ការប្រើសិទ្ធិ និងសេរីភាពខ្លះ ត្រូវហាមឃាត់ :

-សំដែងជាសាធារណៈ នូវគំនិត និងមតិ ឬជំនឿផ្ទាល់ខ្លួនដែលមានលក្ខណៈជាទស្សនៈវិជ្ជា ឬនយោបាយ

-ផ្សព្វផ្សាយនូវអ្វីៗ ដែលធ្វើអោយអន្តរាយដល់សីលធម៌ និងវិន័យរបស់កងយោធពលខេមរភូមិន្ទ

-បង្កើតក្រុមវិជ្ជាជីវៈ ដែលមានលក្ខណៈជាសហជីព

-ធ្វើ ឬចូលរួមបាតុកម្ម និងកូដកម្ម ។

យោធិនដែលពីមុនបានបំរើការងារក្នុងស្ថាប័នរដ្ឋបាលស៊ីវិល ហើយបានចូលជាសមាជិកសហជីព ឬសមាជិកគណបក្សនយោបាយ មុនពេលចូលបំរើកងទ័ព អាចនៅជាសមាជិកដដែល ក៏ប៉ុន្តែមិនអាចធ្វើសកម្មភាពនយោបាយ ឬសហជីពក្នុងពេលខ្លួនកំពុងបំពេញ មុខងារបច្ចុប្បន្នបានឡើយ ។

មាត្រា ១៧.-

យោធិនគ្រប់រូបមានសិទ្ធិក្នុងការតវ៉ាចំពោះអ្នកដែលដាក់ទណ្ឌកម្មខ្លួន ។ បណ្តឹងតវ៉ានេះត្រូវធ្វើតាម

រយៈនាយផ្ទាល់ ហើយបញ្ជូនតាមឋានានុក្រម ។

ក្នុងរយៈពេល៣ខែ ចាប់ពីថ្ងៃដែលបានចុះក្នុងសៀវភៅតវ៉ានៃកងឯកភាពរបស់ខ្លួនរួចមក បើមិនមានចំលើយពីអ្នកដឹកនាំជាន់ខ្ពស់ សាមីខ្លួនអាចធ្វើលិខិតតវ៉ាទៅស្ថាប័នអធិការកិច្ច ដោយភ្ជាប់នូវសំណុំរឿងរបស់ខ្លួនមកជាមួយផង ។ ក្រោយពេលដែលបានទទួលសំណុំរឿងនេះហើយ ស្ថាប័នអធិការកិច្ច ត្រូវផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងការពារជាតិដើម្បីសំរេច ។

សេចក្តីសំរេចរបស់រដ្ឋមន្ត្រី ត្រូវផ្ញើទៅសាមីជនអ្នកតវ៉ាតាមរយៈស្ថាប័នអធិការកិច្ច ហើយត្រូវចុះក្នុងបញ្ជីតវ៉ាកងឯកភាពនោះផង ។

យោធិនដែលតវ៉ា ដោយប្រឌិតហេតុផលមិនសមស្រប ត្រូវទទួលទណ្ឌកម្មធ្ងន់ថែមទៀត ។

មាត្រា ១៨.-

យោធិនគ្រប់រូបមានសិទ្ធិសុំច្បាប់ឈប់សំរាករយៈពេលយូរ និងច្បាប់ឈប់សំរាកសំរាប់ធុរៈក្នុងគ្រួសារផ្ទាល់ ។

ក្នុងកាលៈទេសៈចាំបាច់ អ្នកដឹកនាំអាចកោះហៅយោធិនទាំងនោះអោយចូលមកបំរើការងារវិញ ។

មាត្រា ១៩.-

យោធិនគ្រប់រូប ដែលបានបំរើការជាអចិន្ត្រៃយ៍ក្នុងមុខងារ មានសិទ្ធិសុំច្បាប់ឈប់សំរាក ចំនួន ៤៥ ថ្ងៃក្នុងមួយឆ្នាំតែមួយដង ឬបែងចែកជាច្រើនដង ប៉ុន្តែត្រូវមាន១ដងយ៉ាងតិច ១៥ ថ្ងៃ ។

ការគិតចំនួនថ្ងៃឈប់សំរាកត្រូវកំណត់៤ថ្ងៃក្នុងមួយខែសំរាប់យោធិនដែលមិនបានបំរើការងារពេញមួយឆ្នាំ ។

មាត្រា ២០.-

យោធិនគ្រប់រូបដែលបានចាត់អោយទៅបំពេញការងារ ឬទៅសិក្សាឯបរទេស ដែលមានរយៈពេលចាប់ពី ៦ខែ ឡើងទៅ អាចសុំច្បាប់ឈប់សំរាកបានមុនពេលបេសកកម្ម ចំនួន ១៥ថ្ងៃ ។ ច្បាប់ឈប់សំរាកនេះ មិនត្រូវលើសពី ៣០ថ្ងៃឡើយ ។

ut

មាត្រា ២១.-

យោធិនមានសិទ្ធិសុំច្បាប់ឈប់សំរាកធុរៈគ្រួសារ ។

បែបបទ និងរយៈពេលឈប់សំរាកត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

មាត្រា ២២.-

យោងតាមការចាំបាច់នៃការងារ យោធិនអាចសុំច្បាប់ឈប់សំរាករយៈពេលខ្លីមិនអោយលើសពី ៧២ម៉ោង ។

មាត្រា ២៣.-

សិទ្ធិអនុញ្ញាតច្បាប់ឈប់សំរាកគ្រប់ប្រភេទសំរាប់យោធិន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

ជំពូកទី ៥
បទបញ្ញាក្នុងការចាត់តាំងការងារ

មាត្រា ២៤.-

ក្រៅពីភារកិច្ចក្នុងកងយោធពលខេមរភូមិន្ទ យោធិនគ្រប់រូបត្រូវចូលរួមក្នុងជីវភាពសង្គម ក្នុងកាលៈទេសៈចាំបាច់ដូចជា ការជួយប្រមូលផលប្រជាពលរដ្ឋ ការជួយប្រជាពលរដ្ឋក្នុងពេលមានគ្រោះមហន្តរាយ ការជួយកសាងហេដ្ឋារចនាសម្ព័ន្ធ និងជួយណែនាំប្រជាពលរដ្ឋតាមភូមិ ឃុំ ស្រុក ខេត្តក្រុង ។ល។

ការចូលរួមក្នុងជីវភាពនេះត្រូវបានទទួលការចាត់តាំងពីកងឯកភាពអោយបានទាន់ពេលវេលា ។

មាត្រា ២៥.-

យោធិនគ្រប់រូបអាចដើរហើរពាសពេញយោធភូមិ ដែលខ្លួនកំពុងនៅបំពេញការងារ ក្នុងករណីចេញក្រៅយោធភូមិ យោធិនត្រូវសុំច្បាប់អនុញ្ញាតពីថ្នាក់លើ ។

ក្នុងកាលៈទេសៈចាំបាច់ សេរីភាពដើរហើររបស់យោធិន អាចត្រូវបានកាត់បន្ថយ ។

យោធិន ដែលស្ថិតក្នុងនាវា នៃកងទ័ពជើងទឹកអាចចាកចេញពីនាវាបានតាមលក្ខខណ្ឌ ដែលកំណត់ដោយបទបញ្ជារបស់មេបញ្ជាការនៃកងទ័ពជើងទឹក ។

យោធិនគ្រប់រូប ត្រូវបានចាត់ទុកដូចជា " បំពេញភារកិច្ច " ក្រោមការទទួលខុសត្រូវរបស់រដ្ឋ :

- ក្នុងពេលធ្វើដំណើរក្នុងបរិវេណយោធា

- ក្នុងពេលធ្វើដំណើរក្នុងផ្លូវធម្មតា ចន្លោះទីកន្លែងដែលយោធិនធ្វើសកម្មភាព និងទីកន្លែងដែលអនុញ្ញាតអោយឈប់សំរាក ឬក្នុងចន្លោះទីកន្លែងធ្វើការងារ និងទីកន្លែងស្នាក់នៅ ។

មាត្រា ២៦.-

យោធិននៅក្នុងសាលា ឬក្នុងមជ្ឈមណ្ឌលហ្វឹកហ្វឺន ត្រូវប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងរបស់សាលា ឬមជ្ឈមណ្ឌលនោះ ។

អ្នកដឹកនាំអាចតំរូវដល់យោធិនដែលតាំងទីលំនៅក្នុងភូមិសាស្ត្រ ដែលបានកំណត់ ឬនៅក្នុងលំនៅឋានដែលជាកម្មសិទ្ធិយោធា ។

យោធិនដែលមានតាំងទីលំនៅក្នុងបរិវេណយោធា ត្រូវគោរពបទបញ្ជាដែលបានចែងទុក សំដៅធានាសន្តិសុខ អនាម័យ និងសណ្តាប់ធ្នាប់ក្នុងការសំរាកស្នាក់នៅ ។

មាត្រា ២៧.-

យោធិនគ្រប់រូបក្នុងពេលបំរើការងារ ត្រូវស្លៀកពាក់ឯកសណ្ឋានតាមការកំណត់ជាចាំបាច់ ។ ក្នុងកាលៈទេសៈខ្លះ មេបញ្ជាការអាចអនុញ្ញាត ឬមានបទបញ្ជាអោយស្លៀកពាក់ឯកសណ្ឋានស៊ីវិលក្នុងពេលបំរើការងារ ។

បទបញ្ជាទាំងឡាយដែលផ្ទុយពីបទបញ្ជានេះ អាចអនុញ្ញាតបានដោយមានសេចក្តីសំរេចពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬតាមបទបញ្ជារបស់អគ្គមេបញ្ជាការ ។

ឯកសណ្ឋាននៃកងយោធពលខេមរភូមិន្ទ ត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក ។

យោធិនគ្រប់រូបមិនត្រូវ :

- ស្លៀកពាក់ឯកសណ្ឋានយោធាក្នុងពេលបំរើការងារស៊ីវិល ក្នុងពេលចូលរួមប្រជុំទាំងឡាយ ជាសាធារណៈ ឬឯកជន ដែលមានលក្ខណៈជានយោបាយ ឬបោះឆ្នោតក្នុងសមាគម ឬ សហជីព ។ បើសិនជាមានបញ្ហាពិសេសខ្លះ អាចប្រកាសអោយប្រើតាមបញ្ជារបស់មេបញ្ជាការកងឯកភាព ដោយ

ⲩⲩ

ចាំបាច់ក្នុងកិច្ចបំរើការងារ

- ធ្វើដំណើរដោយគ្មានមួក នៅក្រៅបរិវេណអាគារ និងលូកដៃក្នុងហោប៉ៅខោ ឬអាវ ។ ក៏ប៉ុន្តែពេលធ្វើដំណើក្នុងអាគារ អាចមិនពាក់មួកបាន ។

ការត្រួតពិនិត្យឯកសណ្ឋាន គឺជាការទទួលខុសត្រូវជាអចិន្ត្រៃយ៍នៅគ្រប់លំដាប់ថ្នាក់នៃឋានានុក្រម ។

នៅក្រៅប្រទេស ឯកសណ្ឋានអនុញ្ញាតអោយស្លៀកពាក់បាន សំរាប់យោធិនទាំងឡាយណាដែល :

- បំរើការក្នុងបេសកកម្មទូត ឬចាត់តាំងជាសមាជិកក្នុងបេសកកម្មបច្ចេកទេស
- មានបេសកកម្មជាផ្លូវការ និងរៀនសូត្រនៅឯបរទេស
- សំចតឆ្លងកាត់រវាងប្រទេសនានា ក្នុងឋានៈជាគណៈប្រតិភូយោធា ដើម្បីទៅកាន់ប្រទេសណាមួយផ្សេងទៀត ។

យោធិនទាំងឡាយដែលស្នាក់នៅឯបរទេស ហើយត្រូវចូលរួមក្នុងពិធីជាផ្លូវការ ឬជាឯកជនអាចស្លៀកពាក់ជាឯកសណ្ឋានយោធាបាន ក្នុងករណីមានការអនុញ្ញាតពីរដ្ឋមន្ត្រី ឬមានការព្រមព្រៀង ពីស្ថានតំណាងទូត នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២៨.-

យោធិនគ្រប់រូប អាចស្លៀកពាក់ឯកសណ្ឋានស៊ីវិលបាននៅក្រោយពេលបំរើការងារ និងក្រៅបន្ទាយយោធា លើកលែងតែក្នុងកាលៈទេសៈខ្លះ ដែលមិនអាចអនុញ្ញាតអោយស្លៀកពាក់បាន ។

អាចអនុញ្ញាតអោយស្លៀកពាក់ស៊ីវិល ក្នុងការសហការអនុវត្តការងារទាំងឡាយ ដែលបានទទួលបន្ទុកជាបណ្តោះអាសន្ន ក្នុងបេសកកម្មខ្លះ ។

ប្រភេទមុខងាររបស់យោធិនគ្រប់រូប ដែលអាចអនុញ្ញាតអោយស្លៀកពាក់ស៊ីវិលបានត្រូវសំរេចដោយរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬដោយអគ្គមេបញ្ជាការ ។

ក្នុងលក្ខណៈពិសេស ការអនុញ្ញាតអោយស្លៀកពាក់ឯកសណ្ឋានស៊ីវិលក្នុងម៉ោងធ្វើការ ត្រូវកំណត់ដោយលាយលក្ខណ៍អក្សរ និងសមស្របតាមការណែនាំរបស់ថ្នាក់លើ ។

ក្រៅម៉ោងធ្វើការ យោធិនទាំងឡាយណា ដែលរស់នៅក្នុងបរិវេណយោធា អាចអនុញ្ញាតអោយស្លៀកពាក់ឯកសណ្ឋានស៊ីវិលបាននៅពេលធ្វើដំណើរចេញ ឬចូលមកកាន់កន្លែងវិញ ។

សំលៀកបំពាក់ស៊ីវិលដែលយោធិនស្លៀកពាក់ ត្រូវអោយមានភាពថ្លៃថ្នូរសមរម្យ ។ ហាមស្លៀកពាក់លាយឡំឯកសណ្ឋានយោធាផង ស៊ីវិលផង ឬពាក់កណ្តាលស៊ីវិល ពាក់កណ្តាលយោធា ។

ﾑ

យោធិនគ្រប់រូបជាសិស្សក្នុងសាលាហ្វឹកហ្វឺន បើកាលណាចង់ស្លៀកពាក់ស៊ីវិលក្នុងពេលចេញក្រៅសាលាត្រូវមានការអនុញ្ញាតពីនាយកសាលា តាមការណែនាំពីថ្នាក់លើ ។

មាត្រា ២៩.-

ការកាត់សក់ ការទុកក្រចកដៃ ត្រូវធ្វើអោយបានត្រឹមត្រូវតាមក្បួនអនាម័យ សមនិងឯកសណ្ឋាន ព្រមទាំងសំភារៈបរិក្ខាប្រើប្រាស់ពិសេសផ្សេងទៀត ។ ដូច្នេះចាំបាច់ត្រូវអោយមានការកិតប្រវែងសក់ ។

ទ្រង់ទ្រាយសក់ ត្រូវអោយស្របទៅនឹងទ្រង់ទ្រាយក្បាល និងស្ថានភាពសក់របស់បុគ្គលម្នាក់ៗ ដើម្បីអោយងាយស្រួលក្នុងការសំអាត និងការសំអិតសំអាង ព្រមទាំងអោយមានលក្ខណៈសមរម្យនៅពេលពាក់មួក និងជៀសវាងការមានស្នាមមួកលើសក់ នៅពេលដោះមួកចេញ ។ ដូច្នេះសក់ត្រូវកាត់អោយបានជំរាល ហើយខ្លី ឯជើងសក់ខាងក្រោយ ត្រូវអោយនៅចន្លោះចុងស្លឹកត្រចៀកក្រោម និងកអាវ ។ ចំណែកជើងសក់សង្ខាង ត្រូវអោយបានស្តើងហើយត្រង់ មិនត្រូវទុកជើងក្រោមអោយហួសពីពាក់កណ្តាលស្លឹកត្រចៀក ។

យោធិននារីអាចអនុញ្ញាតអោយទុកសក់វែងត្រឹម ប្រះស្មាសមរម្យតាមរង្វង់មួក ដែលត្រូវពាក់ ។

ចំពោះពលទាហាន នាយទាហានរង សិស្សនាយទាហានសកម្ម ត្រូវទុកសក់ ២ ស.ម ។

ចំពោះនាយទាហានចាប់ពីថ្នាក់អនុសេនីយ៍ឡើង ការទុកសក់ត្រូវអោយបានសមរម្យ ។

ចំពោះពលទាហាន នាយទាហានរង និងនាយទាហាន មិនអនុញ្ញាតអោយទុកពុកមាត់ដាច់ខាត លើកលែងតែមានច្បាប់អនុញ្ញាតពិសេស ពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬពីអគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ។

យោធិនទាំងពីរភេទ មិនអនុញ្ញាតអោយទុកក្រចកដៃវែងបានទេ លើកលែងតែយោធិននារីសិល្បៈ ។

មាត្រា ៣០.-

ការគំនាប់គឺជាកាតព្វកិច្ច ដែលយោធិនម្នាក់ៗត្រូវធ្វើគារវកិច្ច និងជាការបង្ហាញបញ្ជាក់នូវការគួរសមរបស់យោធិនដែលស្លៀកពាក់ឯកសណ្ឋាន។ យោធិនក្នុងពេលបំរើការងារត្រូវគំនាប់ដល់យោធិនទាំងឡាយណាដែលមានឋានន្តរស័ក្តិ ឬតួនាទីធំជាងខ្លួន។ ការគំនាប់នេះគឺជាកាតព្វកិច្ច ដែលយោធិនម្នាក់ៗត្រូវធ្វើដើម្បីសំដែងគារវកិច្ច និងការគួរសមរបស់ខ្លួនដែលស្លៀកពាក់ឯកសណ្ឋាន។ ការគំនាប់នេះអាចអនុវត្តពីរដងក្នុងមួយថ្ងៃ ព្រឹក ល្ងាច។

ការគោរពព្រះមហាក្សត្រ និងព្រះសង្ឃ ត្រូវបានចែងលំអិតនៅក្នុងលំហាត់របៀបដោយឡែក។

យោធិនកាលបើធ្វើដំណើរទៅជួបប្រទះពិធីគោរពទង់ជាតិ ឬទង់កងឯកភាពក្នុងពិធីបុណ្យ ឬហែរក្បួនឬទង់កងឯកភាពបរទេស ត្រូវឈប់ឈរជ្ញើជើងគំនាប់ដោយបែរមុខអោយចំទង់។ ប្រសិនបើជួបប្រទះនាវាចំបាំង ដែលមានទង់ជាតិសញ្ញាសំគាល់ ក៏ត្រូវធ្វើគារវកិច្ចដូចគ្នាដែរ។ ក្នុងពេលចូលរួមពិធីបុណ្យដោយមានការគោរពទង់ជាតិ ឬគ្រាន់តែមានការប្រគុំ ឬចាក់បទភ្លេងជាតិ យោធិនត្រូវក្រោកឈរ ឬឈរប្រុង ហើយគំនាប់លុះត្រាតែចប់បទភ្លេង ទើបសំរាក ឬបន្តដំណើរទៅមុខទៀត។ គ្រប់ពេលវេលា និងគ្រប់ទីកន្លែង យោធិនណាដែលត្រូវកោះហៅដោយនាយទាហាន ឬនាយទាហានរង ដែលមានឋានន្តរស័ក្តិខ្ពស់ជាង ត្រូវប្រញាប់ប្រញាល់រត់ទៅរកដោយឈរជ្ញើជើងគំនាប់ រីឯយោធិន ដែលត្រូវបានគេគំនាប់ក៏ត្រូវទទួលការគំនាប់វិញដោយសមរម្យ។

យោធិនក្នុងកងរាជអាវុធហត្ថ ពេលបំពេញមុខងារជាភ្នាក់ងារកម្លាំងសាធារណៈ អាចគំនាប់បាន ប្រសិនបើគ្មានការជាប់រវល់ក្នុងការបំពេញបេសកកម្មរបស់ខ្លួន។

មាត្រា ៣១.-

បើមានថ្នាក់ឧត្តមសេនីយ៍ណាម្នាក់ ចូលទៅក្នុងកន្លែងធ្វើការណាមួយ យោធិនដែលបានក្រឡេកឃើញមុនគេ ត្រូវស្រែកបញ្ជាថា " តាមកន្លែងរៀងខ្លួន គោរព " បើថ្នាក់វរសេនីយ៍ចូលទៅត្រូវស្រែកបញ្ជាថា " តាមកន្លែង គោរព " បើកាលណាអនុសេនីយ៍វិញ ត្រូវស្រែកបញ្ជាថា " គោរព " បើនាយទាហានរងចុះក្រោម ត្រូវស្រែកបញ្ជាថា " ប្រុង "។

ចំពោះអ្នកទាំងឡាយនៅក្នុងបន្ទប់ ត្រូវប្រញាប់ក្រោកឈរប្រុងយ៉ាងស្ងាត់ស្ងៀម និងស្វាហាប់រហូតដល់មានបញ្ជាអោយសំរាក ទើបអាចសំរាកបាន។ ពេលនាយទាហាន នាយទាហានរងទាំងនោះ

ចេញទៅវិញ យោធិនដែលមានឋានន្តរស័ក្តិធំជាងគេ ឬអ្នកប្រចាំការ ឬគ្រូបង្រៀនក្នុងបន្ទប់នោះ ត្រូវស្រែកបញ្ជាថា " ប្រុង " ទោះថ្នាក់ណាក៏ដោយ ។ ប្រសិនជាឧត្តមសេនីយ៍ នាយទាហាន នាយទាហានរងមានគោលបំណងចង់ទុកពេលអោយបុគ្គលិក ឬសិស្សបន្តការងាររបស់គេ ត្រូវអោយដំណឹងជាមុនតាមយោធិនណាម្នាក់ ដែលនៅធ្វើការក្នុងបន្ទប់នោះ ដោយមិនបាច់ស្រែកបញ្ជាអ្វីទាំងអស់ ពេលដែលខ្លួនចូល និងចេញពីបន្ទប់នោះ ជាពិសេសក្នុងទីបញ្ជាការប្រតិបត្តិការសឹក ។

ម្យ៉ាងទៀតបើនៅក្នុងបន្ទប់រៀន ឬក្នុងការិយាល័យ ឬទីលានដែលយោធិនកំពុងស្ថិតនៅជួបជុំគ្នានោះ ក្នុងករណីមាននាយទាហាន ឬនាយទាហានរងណាម្នាក់ដើរចូលមក តែមានឋានន្តរស័ក្តិតូចជាងនាយទាហាន នាយទាហានរង ដែលស្ថិតនៅក្នុងកន្លែងធ្វើការ យោធិនដទៃទៀតមិនត្រូវស្រែកបញ្ជាអោយគោរពជាដាច់ខាត ។ ផ្ទុយទៅវិញបើនាយទាហាន នាយទាហានរង ដើរចូលមកនោះមានមុខងារជាមេបញ្ជាការផ្ទាល់ និងមានឋានន្តរស័ក្តិស្មើគ្នា យោធិននៅទីនោះ ត្រូវតែស្រែកបញ្ជាអោយគោរពជាដាច់ខាត ។

ក្នុងករណីលើទីលាន ប្រសិនបើយោធិនមួយក្រុមឈរ ឬអង្គុយក៏ដោយ ពេលអ្នកមានបណ្តាស័ក្តិដើរចូលមក យោធិនដែលឃើញមុនគេត្រូវក្រោកឈរ ហើយស្រែកបញ្ជាថា " ប្រុង " ទោះបីអ្នកដើរចូលមក នោះជាថ្នាក់ឧត្តមសេនីយ៍ក៏ដោយ ។

មាត្រា ៣២.-

យោធិនគ្រប់រូប ត្រូវធ្វើការគំនាប់ដល់មន្ត្រីរាជការស៊ីវិល ដែលមានមុខដំណែង និងឋានន្តរស័ក្តិខ្ពស់ជាង ។

ចំពោះនាយទាហានបរទេសណា ដែលមានឋានន្តរស័ក្តិខ្ពស់ជាង យោធិននៃកងយោធពលខេមរភូមិន្ទ ត្រូវធ្វើការគោរពដល់ជនបរទេសនោះ ។

មាត្រា ៣៣.-

យោធិនគ្រប់រូបក្នុងពេលបំពេញបេសកកម្ម ទស្សនកិច្ចក្នុងកងឯកភាពណាមួយ ត្រូវបង្ហាញខ្លួន និងលិខិតបញ្ជាបេសកកម្មដល់មេបញ្ជាការកងឯកភាព ឬអ្នកតំណាងជាចាំបាច់ ។

ᥴᥣ

មាត្រា ៣៤.-

ជាទូទៅក្នុងកន្លែងស្នាក់នៅរបស់យោធាមានជាអាទិ៍ ក្នុងបរិវេណ អាគារ ឬយន្តហោះយោធា ឬនាវា ត្រូវហាមឃាត់ :

- ការលេងល្បែងស៊ីសងគ្រប់ប្រភេទ
- ការនាំចូលដោយគ្មានច្បាប់អនុញ្ញាតនូវគ្រឿងពុល វត្ថុឆាបឆេះ ឬគ្រឿងផ្ទុះ
- ការនាំចូលទស្សនាវដ្តី កាសែត សៀវភៅ ឬការផ្សព្វផ្សាយ ដែលនាំអោយប៉ះពាល់ដល់សីលធម៌ និងវិន័យយោធា ។

មាត្រា ៣៥.-

យោធិនត្រូវរក្សាការសំងាត់យោធា និងមិនត្រូវធ្វើអោយឯកសារយោធាបាត់បង់ ឬធ្លាក់ដល់ដៃអ្នកដទៃ ។

ការប្រើប្រាស់ប្រដាប់ថតរូប ថតភាពយន្ត ឬថតសំលេង ព្រមទាំងប៉ុស្តិ៍វិទ្យុផ្សាយសម្លេងទាំងឡាយ ការផ្សព្វផ្សាយ ការលក់ហ្វីលរូបថត ខ្សែអាត់សំលេង នៅក្នុងបរិវេណយោធា អាគារយោធា លើនាវាយោធា និងលើយន្តហោះយោធា ក្នុងពេលប្រតិបត្តិការ ឬបេសកកម្មយោធាចាំបាច់ត្រូវមានការអនុញ្ញាតពីមេបញ្ជាការ ។

មាត្រា ៣៦.-

នាយទាហាន ឬនាយទាហានរង ក្នុងពេលចូលរួមបញ្ជាដល់យោធិនទាំងឡាយដែលកាន់អាវុធ ឬក្នុងពេលត្រូវអនុវត្តបេសកកម្មពិសេស ចាំបាច់ត្រូវមានអាវុធជាប់នៅនឹងខ្លួន ។

អាវុធទាំងឡាយ ត្រូវប្រើប្រាស់ជាមួយនឹងឯកសណ្ឋានយោធា ក៏ប៉ុន្តែជួនកាលអាចប្រើជាមួយនឹងឯកសណ្ឋានស៊ីវិលបាន បើកាលណាមានការអនុញ្ញាត ឬណែនាំ ពិសេសពីមេបញ្ជាការ ។

ការកាន់អាវុធ និងការប្រើប្រាស់អាវុធផ្ទាល់ខ្លួន ត្រូវមានការអនុញ្ញាតពី អាជ្ញាធរយោធាមានសមត្ថកិច្ច ។

ແ

ជំពូកទី ៦
រង្វាន់

មាត្រា ៣៧.-

យោធិនគ្រប់រូបដែលបំរើការងារ មានសិទ្ធិទទួលរង្វាន់ដូចៗគ្នា ។ រង្វាន់អាចផ្តល់ជូនចំពោះយោធិនម្នាក់ៗ ក្រុម ឬកងឯកភាព ។ការជូនរង្វាន់ត្រូវផ្អែកលើលក្ខណៈសម្បត្តិដូចខាងក្រោម :

- ជាយោធិនគំរូក្នុងការងារ
- មានស្នាដៃពិសេស មានសេចក្តីក្លាហាន
- ហ៊ានបូជាជីវិតចំពោះប្រយោជន៍រួម ចំពោះប្រទេសជាតិ ។

មាត្រា ៣៨.-

រង្វាន់ត្រូវបានចែកចេញជាពីរប្រភេទ គឺរង្វាន់ក្នុងកិច្ចការពិសេស និងរង្វាន់ក្នុងកិច្ចការធម្មតា ។ រង្វាន់ទាំងអស់ត្រូវចុះក្នុងបញ្ជី និងចុះក្នុងសៀវភៅសិក្ខាគារិករបស់យោធិនម្នាក់ៗ ។

គ្រឿងឥស្សរិយយស ត្រូវបានផ្តល់ដល់យោធិនដើម្បីទទួលស្គាល់ស្នាដៃក្នុងការប្រយុទ្ធ មានគុណបំណាច់ខ្ពស់ក្នុងកិច្ចការប្រគល់អោយ ។

ប្រកាសនីយប័ត្រ និងផ្លាកសញ្ញាគ្រឿងឥស្សរិយយស អាចផ្តល់អោយតាមរយៈមេបញ្ជាការ ដើម្បីសំគាល់គុណសម្បត្តិផ្ទាល់ខ្លួន ឬសមត្ថភាពក្នុងការប្រយុទ្ធ ។ មេបញ្ជាការកងយោធពលខេមរភូមិន្ទ អាចផ្តល់រង្វាន់ផ្សេងៗដើម្បីលើកទឹកចិត្តចំពោះលទ្ធផល ដែលបានទទួលក្នុងឱកាសប្រកួតប្រជែង ប្រលងប្រណាំងផ្សេងៗដូចជាលេងកីឡា សិល្បៈ ។ល។ លើកទឹកចិត្តដល់ការប្រឹងប្រែងចំពោះយោធិនណា ដែលខំធ្វើការងារ អោយមានប្រសិទ្ធភាពជឿនលឿន រីកចំរើនក្នុងការងារ និងសំភារៈផ្សេងៗក្នុងកងទ័ព ។

មេបញ្ជាការទាំងឡាយ ដែលមានសិទ្ធិអនុញ្ញាតច្បាប់ អាចផ្តល់ច្បាប់បន្ថែមបានជារង្វាន់ចំនួន ០៥ថ្ងៃក្នុង ១ឆ្នាំ ដល់យុទ្ធជនលើករណី ដែលត្រូវបានច្បាប់ឈប់សំរាកដូចមានចែងក្នុងមាត្រា១៨ ។

ពលទោ និងនាវីកទោទាំងឡាយ ដែលបានបំពេញមុខងារល្អ ហើយមានការចេះដឹងខាងវិជ្ជាយោធា ត្រូវបានទទួលការតែងតាំងពីមេបញ្ជាការ ជាថ្នាក់ពលឯក ឬនាវីកឯក ដោយមិនគិតពីរយៈពេល ដែលបានចូលបំរើក្នុងកងទ័ពឡើយ ។

ll

មាត្រា ៣៩.-

អាជ្ញាធរយោធាដែលមានសិទ្ធិផ្តល់រង្វាន់ដល់យោធិនទាំងឡាយ មានចែងដូចតារាងខាងក្រោម :

ប្រភេទនៃរង្វាន់	អាជ្ញាធរដែលអាចផ្តល់រង្វាន់		
	មេបញ្ជាការកងទ័ពទាំងបីប្រភេទ ជើងទឹក ជើងគោក ជើងអាកាស មេបញ្ជាការយោធភូមិភាគ មេបញ្ជាការកងរាជអាវុធហត្ថ និងមេបញ្ជាការផ្ទាល់	អគ្គមេបញ្ជាការ	រដ្ឋមន្ត្រីក្រសួងការពារជាតិ
គ្រឿងឥស្សរិយយស និងប្រកាសនីយប័ត្រ			
ប័ណ្ណសរសើរ		X	X
លិខិតសរសើរ	X	X	X
រង្វាន់ជារបស់ ឬជាប្រាក់	X	X	X

មេបញ្ជាការផ្ទាល់គឺចាប់ពីថ្នាក់កងពលតូច និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ ។

ជំពូកទី ៧
ទណ្ឌកម្ម វិន័យ

មាត្រា ៤០.-

យោធិនដែលមានការខ្វះខាត និងការធ្វេសប្រហែសក្នុងករណីយកិច្ច ត្រូវទទួលទណ្ឌកម្មផ្នែកវិន័យ និងទទួលទោសតាមច្បាប់ ។

ទណ្ឌកម្មផ្នែកវិន័យ ត្រូវចែងផ្សេងពីទោសល្មើសច្បាប់ ។ កំហុសមួយ អាចទទួលទណ្ឌកម្មផ្នែកវិន័យផង និងទោសតាមច្បាប់ផង ។

ﾠ

ក្រៅពីការព្រមាន ទណ្ឌកម្មផ្នែកវិន័យ ត្រូវចុះក្នុងសៀវភៅសិក្ខាគារិករបស់សាមីយោធិន ។

មាត្រា ៤១.-

ទណ្ឌកម្មផ្នែកវិន័យមានដូចចែងខាងក្រោម :

១-ចំពោះនាយទាហាន និងនាយទាហានរង

- ការព្រមាន
- ការស្ដីបន្ទោស
- ការបន្ទោសដោយលាយលក្ខណ៍អក្សរ ឬ ការផ្អាកមុខដំណែង

២-ចំពោះពលទាហាន

- ការព្រមាន
- ការជាប់បញ្ញត្តិ
- ការផ្អាកមុខដំណែង

មាត្រា ៤២.-

ការបន្ថយឋានន្តរស័ក្តិត្រូវធ្វើចំពោះយោធិនដែលមានកំហុសធ្ងន់ និង ប្រព្រឹត្តល្មើសបទប្បញ្ញត្តិច្រើនដង ។ ការបន្ថយឋានន្តរស័ក្តិនេះត្រូវវិនិច្ឆ័យ និងផ្ដល់យោបល់ពីក្រុមប្រឹក្សាវិន័យ ។

មាត្រា ៤៣.-

យោធិនដែលត្រូវទទួលទណ្ឌកម្មផ្នែកវិន័យ មានសិទ្ធិតវ៉ាពន្យល់ហេតុផលដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរ ចំពោះមេបញ្ជាការឬអ្នកតំណាងដែលបានដាក់ទណ្ឌកម្មនោះ ។

ការដាក់ទណ្ឌកម្ម ត្រូវអនុវត្តទៅតាមអត្រាដាក់ទណ្ឌកម្ម ដូចមានចែងក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ ។

មាត្រា ៤៤.-

យោធិនគ្រប់រូបមានសិទ្ធិអំណាច និងករណីយកិច្ចចាប់ទោស និងស្នើសុំផ្តន្ទាទោសជាកវិន័យតាមកំរិតថ្នាក់ដល់អ្នកនៅក្រោមបង្គាប់បញ្ជា ដោយធ្វើសំណុំបែបបទ ផ្ញើទៅលំដាប់ថ្នាក់ទទួលខុសត្រូវ ដូចខាងក្រោមនេះ :

- មេបញ្ជាការកងឯកភាពផ្ទាល់
- មេបញ្ជាការយោធភូមិភាគ
- មេបញ្ជាការកងទ័ពជើងគោក ជើងទឹក ជើងអាកាស
- អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ
- រដ្ឋមន្ត្រីក្រសួងការពារជាតិ

តារាងកំរិតសិទ្ធិដាក់ទណ្ឌកម្មជាឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

មាត្រា ៤៥.-

ការព្យួរទោសផ្នែករដ្ឋបាលអាចធ្វើទៅបានក្នុងករណីទណ្ឌកម្មស្រាល ។

មិនអនុញ្ញាតអោយព្យួរទោស ចំពោះយោធិន ដែលត្រូវទទួលទណ្ឌកម្មផ្នែកវិន័យ ច្រើនដងមកហើយ ។

មាត្រា ៤៦.-

យោធិនដែលត្រូវដល់កំណត់ឈប់បំរើកងទ័ព ហើយដែលត្រូវជាប់ទណ្ឌកម្ម ត្រូវទទួលទណ្ឌកម្មនោះអោយគ្រប់កំណត់សិន ទើបអាចឈប់បំរើកងទ័ពបាន ។

មាត្រា ៤៧.-

កំហុសដែលអាចនឹងត្រូវប្តឹងទៅតុលាការមានជាអាទិ៍ :

១-កំហុសគេចពីកាតព្វកិច្ចយោធា

- ភាពរឹងរូសមិនគោរពបទបញ្ជា
- យោធិនរត់ចោលជួរ (នៅក្នុងស្រុក)

ഡ

- យោធិនរត់ចោលជួរ (នៅក្រៅស្រុក)
- យោធិនរត់ចោលជួរដោយមានយកអាវុធទៅជាមួយ
- យោធិនរត់ចោលជួរ នៅចំពោះមុខខ្មាំង ឬចុះចូលខ្មាំង
- ការញុះញង់អោយទាហានរត់ចោលជួរ
- ការរួមគំនិតជាមួយអ្នករត់ចោលជួរ
- ការបំពានធ្វើរូបរាងកាយដោយចេតនា

២-កំហុសដែលធ្វើអោយប៉ះពាល់ដល់កិត្តិយស និងករណីយកិច្ច

- ការចុះចាញ់ខ្មាំង
- អំពើក្បត់ជាតិ
- ការប៉ះពាល់ដល់កិច្ចការពារជាតិ
- អំពើប្លន់
- ការរួមគំនិតក្បត់ប្រឆាំង នឹងមេបញ្ជាការជាន់ខ្ពស់
- ការឡើងកាន់មុខដំណែងដោយគ្មានការតែងតាំង
- ការញុះញង់នាំអោយប្រព្រឹត្តិផ្ទុយពីករណីយកិច្ច និងវិន័យយោធា
- ការការពាររថយន្តខុសច្បាប់ និងអំពើរត់ពន្ធផ្សេងៗ
- អំពើលួចលក់ដូរ រត់ពន្ធគ្រឿងញៀន និងបិតិកភ័ណ្ឌជាតិ (វត្ថុបុរាណ)
- ការជំរិតយកប្រាក់ពីអ្នកដំណើរ ពីអាជីវករ
- ការចាប់ជំរិតមនុស្សប្តូរយកប្រាក់
- ការបង្ខូចទឹកចិត្តខុសពីសីលធម៌
- ការបំផ្លាញធ្វើអោយបាត់បង់ ឬខូចខាតដោយចេតនា នូវសំភារៈការពារជាតិ
- ការកែបំបាត់ សំភារៈ អាវុធ គ្រាប់រំសេវ រថយន្ត រថពាសដែក សំលៀកបំពាក់ និងសំភារៈផ្សេងៗទៀត
- ការបន្លំលួចសំភារៈសឹក
- ការលួចទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ

- ការក្លែងបន្លំឯកសណ្ឋាន មេដាយ បដិរូប
- ការកេងប្រវ័ញ្ច ឬក្លែងបន្លំក្នុងកិច្ចការគណនេយ្យ
- ការក្លែងបន្លំនូវគ្រឿងឧបភោគបរិភោគ
- ការបន្លំលួចគ្រឿងបរិក្ខារ បរិក្ខារពេទ្យ និងសំភារៈផ្សេងៗទៀត
- ការលួចតំលើងឋានន្តរស័ក្តិ និងលួចបន្លំចំនួនទ័ព (ទ័ពខ្មោច)
- ការលួចបន្លំលក់អចលនវត្ថុ សម្បត្តិជាតិ (ដីធ្លី ផ្ទះសម្បែង)
- ការធ្វើអោយរាំងស្ទះដល់ការអនុវត្តន៍ ដីកា សាលក្រម ឬសាលដីកាស្ថាពររបស់តុលាការគ្រប់ជាន់ថ្នាក់
- និងបទល្មើសដ៏ទៃទៀតដែលមានចែងក្នុងច្បាប់ជាធរមាន និងលិខិតបទដ្ឋានពាក់ព័ន្ធ ។

៣-កំហុសដែលផ្ទុយនឹងវិន័យយោធា

- ការបះបោរ
- ការបះបោរប្រឆាំងនឹងកំលាំងយោធា និងភ្នាក់ងាររដ្ឋអំណាច
- ការមិនព្រមស្តាប់បង្គាប់ ឬបញ្ជា
- ការរំលោភបំពាននូវច្បាប់កំណែន
- ការបង្កបង្កើតដោយខុសច្បាប់នូវអំណាច ដើម្បីរំលោភទៅលើអ្វីមួយ
- ការប្រព្រឹត្តអំពើឃោរឃៅ ឬប្រមាថយ៉ាងខ្លាំងទៅលើយោធិនក្រោមឱវាទ
- ការប្រមាថជាទម្ងន់ ចំពោះទង់ជាតិ និងកងទ័ព
- ការរំលោភបំពានទៅលើយោធិន អ្នកដែលមានឋានន្តរស័ក្តិធំជាង (ជេរប្រមាថឬសំឡុតគំរាមកំហែង)
- ការប្រព្រឹត្តអំពើឃោរឃៅចំពោះអ្នកយាមកាម
- ការជេរប្រមាថចំពោះអ្នកយាមកាម
- ការប្រព្រឹត្តអំពើឃោរឃៅបំពាន ជេរសំឡុតដល់ភ្នាក់ងារមន្ត្រីរាជការ ។
- និងបទល្មើសដ៏ទៃទៀតដែលមានចែងក្នុងច្បាប់ជាធរមាន និងលិខិតបទដ្ឋានពាក់ព័ន្ធ ។

៤-កំហុសក្នុងការអនុវត្តនីខុសក្បួនខ្នាតរបស់ក្រសួង

- ការមិនគោរពតាមសេចក្តីបង្គាប់ជាទូទៅ ឬផ្ទាល់ចំពោះយោធិនគ្រប់រូប ដែលមានមុខងារនឹងត្រូវអនុវត្ត

- ការបោះបង់ចោលមូលដ្ឋានប្រយុទ្ធនៅចំពោះមុខខ្មាំង

- ការបោះបង់ចោលមូលដ្ឋាននៅពេលសន្តិភាព

- ការបោះបង់ចោលកន្លែងនៅពេលយាមកាម និងពេលដើរត្រួតពិនិត្យ

- ការបោះបង់ចោល កប៉ាល់ យន្តហោះ

- ការដេកនៅពេលយាមកាម ឬនៅពេលត្រួតពិនិត្យបណ្តាលអោយគ្រោះថ្នាក់ និងបាត់សន្តិសុខក្នុងបន្ទាយ ។

៥-កំហុសនិងការធ្វេសប្រហែសផ្ទាល់ខ្លួន

- ការបំផ្លាញធ្វើអោយបាត់បង់ ឬខូចខាតនូវអាគារធំៗ កប៉ាល់ យន្តហោះ រថពាសដែក សព្វាវុធយោធា និងគ្រឿងបំពាក់យោធាដោយមានការធ្វេសប្រហែស

- កំហុសក្នុងការផលិត ឬកែឆ្នៃប្រឌិតដើម្បីធ្វើអាជីវកម្ម នូវអាវុធគ្រាប់រំសេវគ្រឿងផ្ទុះផ្សេងៗ ។

៦-កំហុសផ្សេងៗទៀតមានជាអាទិ:

- ការអោយបញ្ជាដោយខុសច្បាប់

- ការប្រព្រឹត្តអំពើទុច្ចរិត

- ការរៀបចំទុកដាក់ឯកសារមិនត្រឹមត្រូវ (ធ្វើអោយបាត់បង់ ឬធ្លាក់ដល់ដៃអ្នកដទៃ)

- ការធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើភាពថ្លៃថ្នូររបស់កងទ័ព

- ការធ្វេសប្រហែសដោយមិនយកចិត្តទុកដាក់ប្រុងប្រយ័ត្ន ក្នុងកិច្ចការដែលនាំអោយមានគ្រោះ-ថ្នាក់ដល់អាយុជីវិត និងខូចខាតសំភារៈយ៉ាងច្រើន ។

មាត្រា ៤៨.-

អំពើល្មើសពាក់ព័ន្ធទៅនឹងច្បាប់ចរាចរដូចខាងក្រោមត្រូវទទួលទោសតាមវិន័យយោធាផង នឹងអាចត្រូវបញ្ជូនទៅតុលាការ

- ការបើកបរដោយស្រវឹងស្រា
- ការរត់គេចក្រោយពេលមានគ្រោះថ្នាក់
- ការប្រជែងរថយន្តដោយខុសច្បាប់
- ការមិនគោរពសិទ្ធិអ្នកបើកបរ ដែលគេមានសិទ្ធិជាង
- ការមិនគោរពភ្លើងសញ្ញាចរាចរ
- ការបើកល្បឿនហួសកំណត់
- ការបត់ ឬត្រលប់ដោយគ្មានសញ្ញាសំគាល់
- ការមិនគោរពតាមការឆែកឆេរតាមផ្លូវ
- ការមិនគោរពគំនូសចរាចរ ដែលកំណត់តាមផ្លូវ
- ការមិនគោរពសិទ្ធិអ្នកមានអាទិភាពមកពីខាងស្តាំ
- ការចតរថយន្តនៅជិតផ្លូវខ្វែង
- ការបើកភ្លើងហ្វា ដែលនាំអោយចាំងភ្នែកគេ
- ការឈប់រថយន្តនៅខាងឆ្វេងដៃ
- ការមិនព្រមងាកស្តាំ ដោយមានរថយន្តសុំប្រជែង
- ការងាកស្តាំរ៉ាសពេក ក្រោយពេលប្រជែងរថយន្តមុខរួច
- ព្រមទាំងបទល្មើស នឹងច្បាប់ចរាចរ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀត ។

ជំពូកទី ៨
អវសានប្បញ្ញត្តិ

មាត្រា ៤៩.-

បទបញ្ញាទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥០.-

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៥១.-

អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥០
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធអនុក្រឹត្យលេខ.........

ឧបសម្ព័ន្ធទី១.-

តារាងអត្រាដាក់ទណ្ឌកម្ម

ពលទាហាន

ប្រភេទទី ១

កំហុសដែលធំអៀង ដើម្បីគេចអោយផុតពីភារកិច្ចយោធា

ហេតុផល	ទោសកំហុសដែលត្រូវដាក់		
	ការព្រមាន	ការជាប់បញ្ញត្តិ	ការផ្អាកមុខដំណែង
អំពើឈ្លានពានដោយចេតនា -ការធ្វើអោយរបួសខ្លួនឯង ដើម្បីគេចវេះមុខងារ ឬពេលដែល កងឯកភាពនោះចេញប្រតិបត្តិការសឹក -ការធ្វើអោយរបួសខ្លួនឯង ដើម្បីគេចវេះ នៅពេលចុះបំពេញមុខការ ដែលបានទទួលបញ្ជាហើយ -ការប្រព្រឹត្តិអំពើឃោរឃៅ ដោយចេតនា			៣០ថ្ងៃ
អវត្តមានការមិនបង្ហាញខ្លួន -ការមិនឃើញមកដោយស្ម័គ្រចិត្ត ឬដោយធ្វេសប្រហែសធ្ងន់ នៅពេលចេញទៅបំពេញបេសកកម្ម -ការមិនឃើញមក នៅពេលចេញទៅហ្វឹកហាត់ ឬសមយុទ្ធ -ការមិនឃើញមក នៅពេលចេញដំណើររបស់កងឯកភាព ឬការចេញដំណើរទៅបេសកកម្ម			៣០ថ្ងៃ

-ការអវត្តមានហួស ០៦ថ្ងៃ			៦០ថ្ងៃ
-ការអវត្តមានពី០១ថ្ងៃ ទៅ ០៦ថ្ងៃ			៣០ថ្ងៃ
-ការអវត្តមាន ២៤ម៉ោង			៣០ថ្ងៃ
-ការអវត្តមាន ១២ម៉ោង			១៥ថ្ងៃ
-ការអវត្តមាន ០២ម៉ោង		១០ថ្ងៃ	
-ការមិនបានប្រាប់កងឯកភាពខ្លួន នៅពេលចេញទៅធ្វើការមិនទាន់ពេល ដោយដឹងជាមុន		១០ថ្ងៃ	
-ការទៅមិនទាន់ពេល ដើម្បីទៅជាមួយកងឯកភាពខ្លួន ដែលទៅធ្វើកិច្ចការក្រៅបន្ទាយ		១០ថ្ងៃ	
-ការដោះដៃ ឬគេចមុខពីការងារ ដែលត្រូវធ្វើ			២០ថ្ងៃ
-ការគេចខ្លួន ឬប្រាថ្នាគេចខ្លួន នៅពេលដែកឆេះចេញចូលបរិវេណយោធា		៦ថ្ងៃ	

កំណត់ចំណាំ :

ទាហានថ្មី ០៣ខែ រត់ចោលជួរគ្មានទោសពៃរ៍ឡើយ។ ហួសពី ០៦ខែ ទាហានណាបាត់មុខ ២៤ម៉ោង ក្នុងពេលសង្គ្រាម ត្រូវវាយទូរលេខរកសាមីខ្លួន។

បាត់មុខហួសពី១៥ថ្ងៃ ត្រូវចាត់ទុកជារត់ចោលជួរ ហើយផ្ញើសំណុំលិខិតជូនទៅតុលាការ អំពីការ រត់ចោលជួរ ទោះចាប់បាន ឬមិនបានក៏ដោយ។

ពលទាហាន

ប្រភេទទី ២

កំហុសផ្ទុយនឹងកិត្តិយស សេចក្ដីទៀងត្រង់ ឬការគោរពកិច្ចយោធា

ហេតុផល	ទោសកំហុសដែលត្រូវដាក់		
	ព្រមាន	ការដាច់បញ្ញត្តិ	ការផ្អាកមុខដំណែង
-ការខ្វះខាតយ៉ាងធ្ងន់ធ្ងរនឹងកាតព្វកិច្ច និង ការធានាខុសត្រូវ នៅពេលប្រយុទ្ធ			៦០ថ្ងៃ
-ការអោយបញ្ជាដោយល្មើសច្បាប់			៦០ថ្ងៃ
-ការបំពេញអំពើអ្វីមួយ ដែលល្មើស នឹងច្បាប់ ការរួមគំនិត ការញុះញង់ប្រព្រឹត្តនូវការច្របូកច្របល់			៦០ថ្ងៃ
-ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់រាជការ ពេញច្បាប់			៦០ថ្ងៃ
-ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់សីលធម៌ កងទ័ព			៦០ថ្ងៃ
-ការបង្ក ឬញុះញង់អោយធ្វើបាតុកម្ម ការសុំ និងការតវ៉ា ដោយរួមគ្នាជាច្រើន			៦០ថ្ងៃ
-ការឃោសនាប្រឆាំងនឹងយោធា នឹង ជាតិ			៦០ថ្ងៃ
-ការប៉ុនប៉ងបង្វែងដានទាហានម្នាក់ អោយ ចាកផុតពីករណីយកិច្ចរបស់ខ្លួន			៣០ថ្ងៃ
-ការខំប្រឹងប្រែងបង្វែងដាន មិត្តរួមអាវុធ ម្នាក់អោយចេញផុតពីមុខការ និង ករណីយកិច្ច			១៥ថ្ងៃ
-ការមិនប្រឹងប្រែងជួយដល់កិច្ចការរាជការណាមួយ			១៥ថ្ងៃ
-ការមិនជួយធ្វើអន្តរាគមន៍ នៅចំពោះស្ថាន ការណ៍ ដែលត្រូវការអ្នកផ្ដើមគំនិត		១០ថ្ងៃ	
កំហុសដែលប៉ះពាល់ដល់កិត្តិយស			

ល្បីឈ្មោះរបស់កងទ័ព			
-ការបញ្ចេញអាកប្បកិរិយា ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ កេរ្តិ៍ឈ្មោះរបស់កងទ័ព			៦០ថ្ងៃ
-ការមិនគោរព និងការមិនបញ្ចេញមតិ ក្នុងការសរសេរ និងពាក្យសម្តី			១៥ថ្ងៃ
ការបំផ្លាញ ឬបាត់បង់ដោយចេតនា			
-ការវាយបំបែកដោយចេតនា ទៅលើសំភារៈកន្លែង ឬបន្ទប់ណាមួយ			៦០ថ្ងៃ
-ការធ្វើអោយបាត់បង់សំភារៈដោយចេតនា			៦០ថ្ងៃ
-ការធ្វើអោយខូតខាតដោយចេតនា កន្លែង ឬបន្ទប់ណាមួយ សំភារៈតូចៗ និងសំលៀកបំពាក់ទាហាន			៣០ថ្ងៃ
-ការខ្ជះខ្ជាយដោយចេតនា ទៅលើគ្រឿងឧបភោគ បរិភោគយោធា			០៥ថ្ងៃ
ការកែបំបាត់			
-ការយកមកធ្វើជារបស់ខ្លួននូវសព្វាវុធ សំភារៈ និងគ្រឿងឧបករណ៍ផ្សេងៗ របស់រាជការ			១០ថ្ងៃ
-ការលក់គ្រឿងសំភារៈតូចតាច និងគ្រឿងឧបភោគ បរិភោគយោធា			៣០ថ្ងៃ
-យោធបរិក្ខារ-បរិក្ខារពេទ្យ			៣០ថ្ងៃ
អំពើមិនសុចរិត			
-ការប្រព្រឹត្តអំពើមិនសុចរិតយ៉ាងធ្ងន់ធ្ងរ			៦០ថ្ងៃ
-ការប្រព្រឹត្តអំពើមិនសុចរិត			១៥ថ្ងៃ
-ការប៉ុនប៉ងប្រព្រឹត្តសកម្មភាពមិនសុចរិត			២០ថ្ងៃ
-ការបើក ឬប៉ុនប៉ងបើកដោយបង្ខំទូណាមួយ បន្ទប់ណាមួយ ឬកន្លែងណាមួយដែលមានសំភារៈ			៣០ថ្ងៃ
-ការរុករើក្នុងទូ ឬប្រអប់តូចៗ ឬគ្រឿងសំភារៈផ្ទាល់ខ្លួនរបស់អ្នកដទៃ			១០ថ្ងៃ

-ការយកចេញដោយគ្មានការអនុញ្ញាត នូវកូនសោរ ទូណាមួយ បន្ទប់ណាមួយ ឬកន្លែងណាមួយ ដែលគ្មានសំភារៈផ្សេងៗ			២០ថ្ងៃ
-ការល្បងលួងលោមយកខោអាវ តែគ្មានបំណងយកជារបស់ខ្លួនផ្ទាល់			០៥ថ្ងៃ
-ការកែបន្លំតម្លៃ ដែលបានកំណត់អោយ			១០ថ្ងៃ
ការមិនពិត និងការក្លែងក្លាយ			
-ការធ្វើការកាន់កាប់ដោយមិនត្រឹមត្រូវ នៅក្នុងកិច្ចការរបស់គណនេយ្យ			៦០ថ្ងៃ
-ការរៀបចំកាន់កាប់ ដោយមិនត្រឹមត្រូវ នូវឯកសារ			៦០ថ្ងៃ
-ការធ្វេសប្រហែសក្នុងការកាន់កាប់គណនេយ្យ			៣០ថ្ងៃ
-ការធ្វេសប្រហែសក្នុងការរៀបចំឯកសារ			៣០ថ្ងៃ
-ការរៀបចំកាន់កាប់ថវិកាជាតិមិនត្រឹមត្រូវ			៣០ថ្ងៃ
-ការរាយការណ៍មិនជាក់ស្តែង នៅពេលត្រួតពិនិត្យ ឬអង្កេត			៣០ថ្ងៃ
-ការនិយាយកុហកក្នុងក្រសួង ឬរាយការណ៍ខុសដោយចេតនា ឬមិនច្បាស់លាស់			១៥ថ្ងៃ
-ការបោកបញ្ឆោត ឬការប៉ុនប៉ងបោកបញ្ឆោតលើសេចក្តីទុកចិត្តរបស់អ្នកដឹកនាំ			១០ថ្ងៃ
-ការបោកបញ្ឆោត លើសេចក្តីទុកចិត្តរបស់មិត្តភក្តិ		១០ថ្ងៃ	
-ការកាន់ច្បាប់អនុញ្ញាតអោយឈប់សំរាក ដោយបន្លំ ឬក្លែងក្លាយច្បាប់ឈប់សំរាក			១០ថ្ងៃ
-ការអនុញ្ញាត ឬចុះហត្ថលេខាលើលិខិតស្នាម ដោយគ្មានសិទ្ធិនឹងចុះហត្ថលេខា			០៨ថ្ងៃ
-ការប្រើប្រាស់ដោយបន្លំ នូវត្រា ក្រដាសស្នាម ឬក្រដាសពុម្ពរបស់ក្រសួង			១០ថ្ងៃ

-ការផ្តល់អាស័យដ្ឋានមិនពិត នៅពេលចេញទៅច្បាប់			០៨ថ្ងៃ
-ការបង្ហាញអត្តសញ្ញាណប័ណ្ណ ដោយប្រើឈ្មោះខុស			១០ថ្ងៃ
-ការបន្លំចំនួនទាហានពិត ដោយគិតទុកជាមុន នៅពេលប្រជុំជួរ			០៨ថ្ងៃ

ពលទាហាន

ប្រភេទទី ៣

កំហុសផ្ទុយនឹងវិន័យយោធា

ហេតុផល	ទោសកំហុស ដែលត្រូវដាក់		
	ការព្រមាន	ការជាប់បញ្ញត្តិ	ការផ្អាកមុខដំណែង
ការប៉ះពាល់ដល់អព្យាក្រឹតភាពកងទ័ព			
-ការប៉ះពាល់ អព្យាក្រឹតភាពកងទ័ព			៦០ថ្ងៃ
ការរឹងរូសមិនចំណុះ			
-ការបានដឹកនាំ ថ្នាក់ក្រោមបង្គាប់អោយធ្វើការតវ៉ារួមគ្នាជាច្រើន ឱយប្រឆាំងនឹងមុខការ			៤៥ថ្ងៃ
-ការបានដឹកនាំមិត្តភក្តិឯទៀត ដោយស្រុះស្រួលគ្នា ដើម្បីសុំ ឬធ្វើបាតុកម្ម ប្រឆាំងនឹងមុខការ			៣០ថ្ងៃ
-ការបានទៅរួបរួមគ្នា នៅក្នុងការតវ៉ា			៣០ថ្ងៃ

និងការបះបោរប្រឆាំងនឹងមុខការ			
-ការតវ៉ាដោយសំអាងលើអ្វីមួយ ដែលមិនត្រឹមត្រូវ ដោយមិនបានគិតទុកជាមុន			៣០ថ្ងៃ
-ការសរសេរទៅថ្នាក់លើដោយមិនគោរពតាមឋានានុក្រម			០៥ថ្ងៃ
ការមិនគោរពតាម			
-ការមិនគោរពតាម ដោយជាក់លាក់នូវបទបញ្ជា			៦០ថ្ងៃ
-ការមិនព្រមអនុវត្តបញ្ជា រហូតមានអន្តរាគមន៍ពីថ្នាក់លើ			០៨ថ្ងៃ
-ការមិនគោរពតាមបង្គាប់ជាដាច់ខាតទី១		១០ថ្ងៃ	
-ការមិនគោរពតាម នូវបទបញ្ជាដោយចេតនា		១០ថ្ងៃ	
-ការអនុវត្តន៍តាមបញ្ជាដោយយឺតយ៉ាវ	X		
-ការមិនស្របតាម នូវបញ្ជា ដែលបានទទួល	X		
-ការមិនគោរពគ្រូបង្ហាត់			១០ថ្ងៃ
ការរំលោភអំណាច			
-ការធ្វើទុក្ខបុកម្នេញយ៉ាងធ្ងន់ធ្ងរ ដល់អ្នកក្រោមបង្គាប់ ឬមនុស្សណាមួយក្រោមឱវាទរបស់ខ្លួន			៦០ថ្ងៃ
-ការប្រព្រឹត្តិអំពើគំរោះគំរើយ ដល់អ្នកនៅក្រោមបង្គាប់ ឬជនណាមួយនៅក្រោមឱវាទរបស់ខ្លួន			៣០ថ្ងៃ
-ការធ្វើបាបទៅលើអ្នក នៅក្រោមបង្គាប់ ឬក្រោមឱវាទ			២០ថ្ងៃ

-ការរំលោភសិទ្ធិអ្នកនៅក្រោមបង្គាប់			១០ថ្ងៃ
ការប្រមាថលើរូបកាយ និងបំពាន			
-ការប្រមាថមើលងាយដល់ទង់ជាតិ ឬ កងទ័ព			៦០ថ្ងៃ
-ការភ្លេចគោរពទង់ជាតិ			១០ថ្ងៃ
-ការរំលោភ ការកំហែង ការប្រទេចប្រទាំង ការឆ្លើយត្រគោះបោះបោក ដល់អ្នកមានបណ្ដាស័ក្តិធំជាង			៦០ថ្ងៃ
-ការបណ្ដោយអោយនរណាម្នាក់ ធ្វើទុក្ខបុកម្នេញ			៦០ថ្ងៃ
-ការខ្វះខាតក្នុងការគោរព និងអាកប្បកិរិយាប្រទេចប្រទាំងដល់អ្នកមានបណ្ដាស័ក្តិ ធំជាង			៣០ថ្ងៃ
-ការគំរាមកំហែងដើម្បីទីងដាក់ពាក្យតវ៉ា			១០ថ្ងៃ
-ការតំរោះតំរើយចំពោះអ្នកយាម ឬភ្នាក់ងារមានសមត្ថកិច្ច			៦០ថ្ងៃ

ពលបាហាន

ប្រភេទទី ៤

ការខ្វះខាតក្នុងការអនុវត្តន៍ជាផ្លូវការ

ហេតុផល	ទោសកំហុស ដែលត្រូវដាក់		
	ការព្រមាន	ការជាប់បញ្ញត្តិ	ការផ្អាកមុខដំណែង
-ការខ្វះខាតយ៉ាងធ្ងន់ធ្ងរ ចំពោះក្បួនច្បាប់ នៃ ការងារ បទល្មើសចំពោះសេចក្តីបង្គាប់អាជ្ញា			៦០ថ្ងៃ
-ការប្រព្រឹត្តិបទល្មើសដោយគិតទុកជាមុន (ដោយចេតនា) ក្នុងវិន័យយោធា ឬក្នុងសេចក្តី បង្គាប់			៣០ថ្ងៃ
-ការមិនស្តាប់បង្គាប់ ការបង្គាប់របស់អ្នកយាម			២០ថ្ងៃ
-ការមិនបានប្រព្រឹត្តិតាមវិន័យយោធា និង សេចក្តីបង្គាប់ការ			១៥ថ្ងៃ
-ការប៉ុនប៉ងប្រព្រឹត្តិបទល្មើស ចំពោះវិន័យយោធា ឬសេចក្តីបង្គាប់ការ			១០ថ្ងៃ
-ការធ្វើវិយោគក្នុងមុខងារ ឬការទទួលខុសត្រូវ ឬការបណ្តោយអោយមានការប្រព្រឹត្តិបទល្មើសចំពោះវិន័យកងទ័ព រាល់បទបញ្ជា ឬរាល់សេចក្តីបង្គាប់			៣០ថ្ងៃ
-ការមិនប្រព្រឹត្តិតាមកិច្ចសន្យា បញ្ញត្តិ សេចក្តីបង្គាប់ការ និងវិន័យយ៉ាងល្អិតល្អន់ (វិន័យពិសេសនៅក្នុងធរមានបញ្ញត្តិ ក្នុងកងឯកភាព ឬក្នុងជួរកងទ័ព)			១០ថ្ងៃ

-ការធ្វេសប្រហែសក្នុងការប្រព្រឹត្តិតាម សេចក្តីបង្គាប់ ឬបញ្ញត្តិណាមួយ			១០ថ្ងៃ
ការបោះបង់មូលដ្ឋាន			
-ការចាកចេញពីមូលដ្ឋាន ដោយគ្មានសេចក្តីអនុញ្ញាត			៦០ថ្ងៃ
-ការមិនទៅដល់មូលដ្ឋាន ដែលបានកំណត់អោយទៅបំរើការងារ			៣០ថ្ងៃ
-ការអវត្តមានតែមួយស្របក់ នៅក្នុងកន្លែងបំពេញការងារ			២០ថ្ងៃ
-ការអវត្តមានតែមួយស្របក់ ដោយមិនចេញឆ្ងាយពីមូលដ្ឋាន		០៦ថ្ងៃ	
-ការបោះបង់ចោលកន្លែងហ្វឹកហាត់ ឬកិច្ចការផ្សេងៗ ដែលបានកំណត់អោយ			១០ថ្ងៃ
-ការដែលនៅក្នុងករណីជិនូសមុខការ ដោយគ្មានការអនុញ្ញាត			១០ថ្ងៃ
-ការដែលនាយរថយន្ត ឬអ្នកបើកបរ បានចាកចេញពីរថយន្តដោយឥតច្បាប់ផ្ញើទុកនឹងគេ ដោយគ្មានច្បាប់អនុញ្ញាត នូវរថយន្ត ឬទូកក្តាររបស់ខ្លួនកាន់កាប់			១៥ថ្ងៃ
-ការចាកចេញពីរថយន្តរយៈពេលខ្លី (មួយស្របក់) ដោយគ្មានច្បាប់អនុញ្ញាត			០៦ថ្ងៃ
ការខ្វះខាតនៅក្នុង កិច្ចការយាមកាមពេលយប់ និងប្រចាំការ			
-ការធ្វេសប្រហែស ក្នុងកិច្ចការយាមកាម កិច្ចការត្រួតពិនិត្យ			៦០ថ្ងៃ
-ការដេកក្នុងពេលយាមកាម និងការត្រួតពិនិត្យ			១៥ថ្ងៃ

-កំហុសយ៉ាងធ្ងន់ទៅលើការត្រួតពិនិត្យ ពូកប្រចាំការ នាយប្រចាំសប្តាហ៍ នាយយាមកាម នាយត្រួតពិនិត្យ ១៥នាទីម្តង និងអ្នកយាមល្បាត ក្រុមទាហានដែលរៀបចំជាស្រេច នៅពេលចេញប្រតិបត្តិការ		១០ថ្ងៃ	
-ការមិនបានដើរល្បាត តាមស្ថានភាព ដែលបានកំណត់ឱ្យ			១០ថ្ងៃ
-ការដើរចោលទីកន្លែង ក្នុងអំឡុងពេលយាមកាម ១៥ នាទីម្តង ដោយគ្មានអ្នកជំនួស			០៦ថ្ងៃ
-ការមិនងើបពីដេក ដល់ពេលវេលាត្រូវយាមកាម		០៤ថ្ងៃ	
-ការមកយឺត ក្នុងពេលយាមកាម	X		
ការប្រព្រឹត្តិបទល្មើស មកមិនទាន់ពេលវេលានៅពេលបំពេញមុខងារ			
-ការមកមិនទាន់ពេលធ្វើការឬការចេញពីធ្វើការមុនម៉ោង		១០ថ្ងៃ	
-ការអនុវត្តនីការងារមិនល្អដោយចេតនា	X		
-ការមានបំណងមិនល្អជានិច្ចកាល នៅក្នុងមុខងារ			៣០ថ្ងៃ
-ការមិនបានព្យាបាលខ្លួន នៅពេលមានជម្ងឺដើម្បីគេចវេះពីមុខងារ			១៥ថ្ងៃ
-ការដែលបង្ហាញខ្លួន នៅពេលទៅមន្ទីរពេទ្យ ដោយសាមីខ្លួនមានជម្ងឺគេចវេះពីការងារ		០៨ថ្ងៃ	
-ការមិនបានទៅ នៅពេលចេញទៅហ្វឹកហ្វឺន		០៤ថ្ងៃ	
-ការមិនបានទៅបង្ហាញខ្លួន នៅពេលត្រួតពិនិត្យ		១០ថ្ងៃ	
ការប្រព្រឹត្តិទូវក្បួនខ្នាត សន្តិសុខ និងសេចក្តីបង្គាប់ជាដាច់ខាតនៃអនាម័យ			
-ការខ្វះខាត និងអនុវត្តក្បួនខ្នាតសន្តិសុខ		០៤ថ្ងៃ	
-ការខ្វះខាត និងអនុវត្តក្បួនខ្នាតអនាម័យ		០៤ថ្ងៃ	
-ការជក់បារី ធ្វើអោយភ្លើងឆេះនៅជិតឃ្លាំងគ្រាប់			៣០ថ្ងៃ

ឃ្លាំងសាំង និងឃ្លាំងដែលមានគ្រឿងផ្ទុះ			
-ការលេងអាវុធ លេងគ្រាប់ដោយគ្មានច្បាប់			១០ថ្ងៃ
-ការមិនអនុវត្តតាមសេចក្តីបង្គាប់របស់ពេទ្យ		០៨ថ្ងៃ	
-ការបោលកំទេច ឬកាកអ្វីក្រៅពីកន្លែងបានកំហិតឱ្យ		០៤ថ្ងៃ	
-ការនាំចូលនូវអាវុធផ្ទាល់ខ្លួន ក្នុងបរិវេណទាហាន ដោយគ្មានការអនុញ្ញាត			២០ថ្ងៃ
-ការកាន់អាវុធ គ្រាប់បែក គ្រឿងផ្ទុះ ដោយខុសច្បាប់			២០ថ្ងៃ
-ការកែប្រែនូវសំភារៈសព្វាវុធ គ្រាប់រំសេវទាំងឡាយ ដោយគ្មានច្បាប់			២០ថ្ងៃ
-ការឃោតយល់ ជួយអោយប្រព្រឹត្តនូវគ្រឿងញៀន			៦០ថ្ងៃ
-ការប្រើប្រាស់គ្រឿងញៀន			៣០ថ្ងៃ
-ការនាំចូលដោយគ្មានច្បាប់អនុញ្ញាត ក្នុងបរិវេណទាហាន មានគ្រឿងញៀន មានជាតិស្រា និងគ្រឿងផ្ទុះ			៣០ថ្ងៃ
-ការញុះញង់អោយប្រើគ្រឿងស្រវឹងដោយហួសហេតុ			២០ថ្ងៃ
-ការប្រព្រឹត្តិមិនស្អាតស្អំ			០៨ថ្ងៃ
-ការចេញចូលក្នុងកន្លែងហាមឃាត់			០៨ថ្ងៃ
-បទល្មើសនឹងច្បាប់ក្នុងការហាមជក់បារី			០៨ថ្ងៃ
-ការហាលខោអាវមិនតាមច្បាប់ទម្លាប់	X		
-ការដេកខុសកន្លែង ដែលបានកំណត់អោយ		០២ថ្ងៃ	
-ការងូតទឹកមិនត្រឹមត្រូវ	X		
-ការមិនថែទាំសំភារៈ និងលុយកាក់ផ្ទាល់ខ្លួន		១០ថ្ងៃ	
ការហាមឃាត់ផ្សេងៗ			
-ការមិនអនុវត្តតាមក្បួនច្បាប់ នៅពេលដែលយើងទៅសំរាកនៅប្រទេសក្រៅ			១០ថ្ងៃ
-ការនាំមនុស្សក្រៅចូលក្នុងបរិវេណយោធា			១៥ថ្ងៃ
ការប្រើប្រាស់ដោយគ្មានសណ្តាប់ធ្នាប់ យានជំនិះ ឬសំភារៈយោធា			

-ការប្រើប្រាស់ដោយគ្មានច្បាប់ ហើយគ្មានសណ្តាប់ធ្នាប់ នូវយានជំនិះ និងសំភារៈយោធា			៣០ថ្ងៃ
-ការបង្វែងដានដោយចេតនា នូវគោលដៅដែលត្រូវទៅ			០៨ថ្ងៃ
-ការដឹកនាំជនស៊ីវិលតាមរថយន្តយោធា ដោយគ្មានច្បាប់អនុញ្ញាត			១៥ថ្ងៃ
-ការដឹកនាំយោធា និងសំភារៈផ្សេងៗ ដោយគ្មានច្បាប់អនុញ្ញាត			០៨ថ្ងៃ
-ការប្រើប្រាស់សំភារៈរាជការដោយគ្មានច្បាប់ សំរាប់ប្រ យោជន៍ផ្ទាល់ខ្លួន			២០ថ្ងៃ
បទល្មើសនឹងច្បាប់ ក្នុងកិច្ចការពារការសម្ងាត់			
-ការមិនចេះលាក់នូវអាថ៌កំបាំង ដោយវោហារ ឬសរសេរ ដែលបណ្តាលអោយមានវិបត្តិយ៉ាងធ្ងន់			៣០ថ្ងៃ
-ការទាក់ទងជាមួយមនុស្ស ដែលគ្មានសមត្ថភាព ដែលដឹងការសម្ងាត់			៣០ថ្ងៃ
-ការធ្វើអោយបាត់បង់ឯកសារ			៣០ថ្ងៃ
-ការកាន់កាប់ឯកសារដោយគ្មានច្បាប់អនុញ្ញាត			១០ថ្ងៃ
-ការធ្វេសប្រហែសក្នុងការរាយការណ៍ ពីការបាត់បង់ ខូចខាតសំភារៈ គ្រោះថ្នាក់ក្នុងពេលដែលយើងគ្រប់គ្រង			១៥ថ្ងៃ

ពលដាហាន

ប្រភេទទី ៥

កំហុសនិងការធ្វេសប្រហែស នៅក្នុងមុខងារ

ហេតុផល	ទោសកំហុសដែលត្រូវដាក់		
	ការព្រមាន	ការជាប់បញ្ញត្តិ	ការផ្អាកមុខដំណែង
-ការមានកំហុសជាទម្ងន់ ដោយធ្វេសប្រហែស នៅក្នុងមុខងារ ដែលបណ្តាលអោយមានគ្រោះថ្នាក់ដល់អាយុជីវិត ឬការខូចខាតយ៉ាងធ្ងន់ដល់សំភារៈ			៦០ថ្ងៃ
-ការបាត់បង់សំភារៈសំខាន់ៗ និងឯកសារ ផ្សេងៗ			២០ថ្ងៃ
-ការមិនរាយការណ៍នៅពេលបាត់ អត្តសញ្ញាណប័ណ្ណ			១០ថ្ងៃ

ពលធាហារ

ប្រភេទទី ៦

កំហុសប៉ះពាល់ដល់កិរិយាមារយាទល្អ

(កំហុសអាកប្បកិរិយា និងឯកសណ្ឋាន)

ហេតុផល	ទោសកំហុសដែលត្រូវដាក់		
	ការព្រមាន	ការជាប់បញ្ញត្តិ	ការផ្អាកមុខដំណែង
-ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិរិយាមារយាទ បទល្មើសក្នុងការស្លៀកពាក់ឯកសណ្ឋាន			៦០ថ្ងៃ
-ការស្លៀកពាក់ឯកសណ្ឋានផ្ទុយនឹងអនុក្រឹត្យ នៅក្នុងបរិវេណអង្គភាពទ័ព			១៥ថ្ងៃ
-ការស្លៀកពាក់ឯកសណ្ឋាន ផ្ទុយនឹងបទបញ្ជាផ្ទៃក្នុង នៅក្នុង ឬក្បែរបរិវេណកងទ័ព			០៨ថ្ងៃ
-ការស្លៀកពាក់ឯកសណ្ឋានផ្លែសផ្លាស គគ្រិច នៅក្រៅបរិវេណអង្គភាព			០៨ថ្ងៃ
-ការស្លៀកពាក់ឯកសណ្ឋានផ្លែសផ្លាស់ គគ្រិច នៅក្នុង ឬក្បែរបរិវេណអង្គភាព		១០ថ្ងៃ	
-ការដែលមិនស្លៀកពាក់ សមស្របតាមបទប្បញ្ញត្តិ		០២ថ្ងៃ	
-ការប្រើប្រាស់ឯកសណ្ឋានស៊ីវិលហើបារហូសហេតុក្នុងបរិវេណយោធា		១០ថ្ងៃ	
កំហុសក្នុងការប្រព្រឹត្តិ			

-ការប្រព្រឹត្តិទុរាចារកម្ម			៣០ថ្ងៃ
-ការបង្កហេតុ ធ្វើអោយគ្មានសណ្តាប់ធ្នាប់ក្នុងពេលបំពេញការងារ ឬចេញប្រតិបត្តិការ			៣០ថ្ងៃ
-ការបង្កហេតុ ឬប្រព្រឹត្តិបាបកម្មនៅក្រៅបរិវេណកងឯកភាព			២០ថ្ងៃ
-ការបង្កហេតុ ឬប្រព្រឹត្តិបាបកម្មនៅក្នុងបរិវេណកងឯកភាព			១០ថ្ងៃ
-ការស្រវឹងស្រា ដែលនាំអោយរាំងស្ទះក្នុងកិច្ចការ			៣០ថ្ងៃ
-ការស្រវឹងស្រា នៅពេលបំពេញកិច្ចការ			១៥ថ្ងៃ
-ការស្រវឹងស្រា ប្រព្រឹត្តិបាបកម្មនៅក្រៅបរិវេណកងឯកភាព			៣០ថ្ងៃ
-ការស្រវឹងស្រា ប្រព្រឹត្តិបាបកម្មនៅក្នុងបរិវេណកងឯកភាព			២៥ថ្ងៃ
-ការស្រវឹងស្រា			១០ថ្ងៃ
-ការធ្វើទុក្ខបុកម្នេញ ចំពោះមិត្តភក្តិ			៦០ថ្ងៃ
-ការធ្វើទុក្ខបុកម្នេញធម្មតា			២០ថ្ងៃ
-ការមិនបានធ្វើអន្តរាគមន៍ នៅពេលឃើញគេធ្វើទុក្ខបុកម្នេញអ្នកដទៃ			២០ថ្ងៃ
-ការប្រព្រឹត្តិអំពើឃោរឃៅ ធ្វើអោយបាក់មុខមាត់ ដោយអាម៉ាស់ទៅលើមិត្តភក្តិ			៣០ថ្ងៃ
-ការរូមគំនិត ធ្វើអោយអាម៉ាស់ ឬបាក់មុខមាត់			១០ថ្ងៃ
-ការជាល់តប់ ឬឈ្លោះប្រកែកគ្នា			១៥ថ្ងៃ
-ការផលិត ឬកែច្នៃសម្រាប់ធ្វើអាជីវកម្មទិញលក់អាវុធ គ្រាប់រំសេវ ជាតិផ្ទុះផ្សេងៗ			៦០ថ្ងៃ

តារាងអត្រាទណ្ឌកម្ម

នាយទាហានរង

ប្រភេទទី ១

កំហុស ដែលសំរៀងដើម្បីគេចអោយផុតពីភារកិច្ចយោធា

ហេតុផល	ទោសកំហុសដែលត្រូវដាក់		
	ការព្រមាន	ការស្តីបន្ទោស	ការស្តីបន្ទោសដោយលាយល័ក្ខណអក្សរ ឬការផ្អាកមុខដំណែង
អំពើឈ្លានពានដោយចេតនា			
-ការធ្វើអោយរបួសខ្លួនឯង ដើម្បីគេចវេះមុខងារ ឬពេលដែលកងឯកភាពនេះចេញប្រតិបត្តិការ សឹក			៦០ថ្ងៃ
-ការធ្វើអោយរបួសខ្លួនឯង ដើម្បីគេចវេះទៅ ពេលចេញទៅ បំពេញមុខការ ដែលបានទទួល បញ្ជាហើយ			២០ថ្ងៃ
-ការប្រព្រឹត្តិអំពើឃោរឃៅដោយចេតនា			៤៥ថ្ងៃ
អវត្តមានការមិនបង្ហាញខ្លួន			
- ការមិនឃើញមកដោយមិនស្ម័គ្រចិត្ត ឬដោយ ធ្វេសប្រហែសធ្ងន់ ទៅពេលចេញទៅបំពេញ បេសកកម្ម			៦០ថ្ងៃ
-ការមិនឃើញមក នៅពេលចេញដំណើរទៅ ហ្វឹកហាត់ ឬសមយុទ្ធ			៣០ថ្ងៃ
-ការមិនឃើញមក នៅពេលចេញដំណើររបស់កងឯកភាព ឬការចេញដំណើរទៅបេសកកម្ម			៣០ថ្ងៃ

-ការអវត្តមានហួសពី០៦ថ្ងៃ			៤៥ថ្ងៃ
-ការអវត្តមានពី០១ថ្ងៃទៅ០៦ថ្ងៃ			៤៥ថ្ងៃ
-ការអវត្តមាន២៤ម៉ោង			៤៥ថ្ងៃ
-ការអវត្តមាន១២ម៉ោង			២០ថ្ងៃ
-ការមិនបានប្រាប់កងឯកភាពខ្លួន នៅពេលដែល ចេញទៅធ្វើការមិនទាន់ពេលដោយដឹងជាមុន	X		
-ការទៅមិនទាន់ពេល ដើម្បីទៅជាមួយកងឯកភាពខ្លួនដែលទៅធ្វើកិច្ចការក្រៅបន្ទាយ	X		
-ការដោះដៃ ឬគេចមុខការដែលត្រូវធ្វើ			៣០ថ្ងៃ
-ការគេចខ្លួន ឬប្រាថ្នាគេចខ្លួន ដែលដែកនេរ ចេញ ចូលបរិវេណយោធា			២០ថ្ងៃ

កំណត់ចំណាំ:

ទាហានថ្មី ០៣ខែរត់ចោលជួរគ្មានទោសពៃរ៍ឡើយ ។ ហួសពី០៦ខែ ទាហានណាបាត់មុខ ២៤ម៉ោង ក្នុងពេលសង្គ្រាម ត្រូវវាយទូរលេខរកសាមីខ្លួន ។

បាត់មុខហួសពី១៥ថ្ងៃ ត្រូវចាត់ទុកជារត់ចោលជួរ ហើយផ្ញើសំណុំលិខិតទៅតុលាការ អំពីការរត់ចោលជួរ ទោះចាប់បាន ឬមិនបានក៏ដោយ ។

នាយទាហានរង

ប្រភេទទី ២

កំហុសផ្ទុយនឹងកិត្តិយស សេចក្តីទៀងត្រង់ ឬកាតព្វកិច្ចយោធា

ហេតុផល	ទោសកំហុសដែលត្រូវដាក់		
	ការព្រមាន	ការស្តីបន្ទោស	ការស្តីបន្ទោសដោយលាយល័ក្ខណ៍អក្សរ ឬការផ្អាកមុខដំណែង
-ការខ្វះខាតយ៉ាងធ្ងន់ចំពោះ កាតព្វកិច្ច និងការធានាខុសត្រូវ នៅពេលប្រយុទ្ធ			៦០ថ្ងៃ
-ការអោយបញ្ជាដោយល្មើសច្បាប់ ផ្ទុយនឹង ច្បាប់			៦០ថ្ងៃ
-ការបំពេញអំពើអ្វីមួយ ដែលល្មើសនឹងច្បាប់			៦០ថ្ងៃ
ការរួមគំនិត ការញុះញង់ប្រព្រឹត្តនូវ ការច្របូកច្របល់			
-ការប៉ះពាល់យ៉ាងធ្ងន់ដល់រាជការពេញច្បាប់			៦០ថ្ងៃ
-ការប៉ះពាល់យ៉ាងធ្ងន់ដល់ សីលធម៌កងទ័ព			៦០ថ្ងៃ
-ការបង្ក ឬញុះញង់អោយធ្វើបាតុកម្ម ការសុំ និងការតវ៉ាដោយរួមគ្នាជាច្រើន			៦០ថ្ងៃ
-ការឃោសនាប្រឆាំងនឹងយោធា នឹងជាតិ			៦០ថ្ងៃ
-កាប៉ុនប៉ងបង្វែងដានទាហានម្នាក់ អោយចាកផុតពីករណីយកិច្ច របស់ខ្លួន			៤៥ថ្ងៃ

-ការខំប្រឹងបង្វែងដានមិត្តរួមអាវុធម្នាក់អោយចេញផុតពីមុខការ និងករណីយកិច្ច			៣០ថ្ងៃ
-ការមិនប្រឹងប្រែងជួយកិច្ចការ រាជ-ការណាមួយ			១០ថ្ងៃ
-ការមិនជួយធ្វើអន្តរាគមន៍ ចំពោះស្ថានការណ៍ ដែលត្រូវការអ្នកផ្តើមគំនិត			១៥ថ្ងៃ
កំហុសដែលប៉ះពាល់ដល់កិត្តិយសល្បីឈ្មោះ របស់កងទ័ព			
-ការបញ្ចេញអាកប្បកិរិយា ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរកេរ្តិ៍ឈ្មោះកង-ទ័ព			៦០ថ្ងៃ
-ការមិនគោរព និងមិនបញ្ចេញមតិក្នុងការ សរសេរ និងពាក្យសំដី			៣០ថ្ងៃ
ការបំផ្លាញ ឬបាត់បង់ដោយចេតនា			
-ការវាយបំបែកដោយចេតនាទៅលើសំភារៈនៅហ្នឹងកន្លែង ឬ បន្ទប់ណាមួយ			៦០ថ្ងៃ
-ការធ្វើអោយបាត់បង់សំភារៈ ទាំង-ឡាយ ដោយចេតនា			៦០ថ្ងៃ
-ការធ្វើអោយខូចខាតដោយចេតនាកន្លែង ឬបន្ទប់ ណាមួយ នូវសំភារៈតូចៗ និងសំលៀកបំពាក់ទាហាន			១៥ថ្ងៃ
-ការខ្ជះខ្ជាយដោយចេតនា ទៅលើគ្រឿងឧបភោគ បរិភោគ			១០ថ្ងៃ

ការកែបំបាត់			
-ការយកមកធ្វើជារបស់ផ្ទាល់ខ្លួន នូវសព្វាវុធ សំភារៈ និងគ្រឿងឧបករណ៍ ផ្សេងៗរបស់រាជការ			៣០ថ្ងៃ
-ការលក់គ្រឿងសំភារៈតូចតាច និងគ្រឿងឧបភោគ បរិភោគយោធា			៣០ថ្ងៃ
-យោធបរិក្ខារ-បរិក្ខារពេទ្យ			៦០ថ្ងៃ
អំពើមិនសុចរិត			
-ការប្រព្រឹត្តិអំពើមិនសុចរិតយ៉ាងធ្ងន់ធ្ងរ			៦០ថ្ងៃ
-ការប្រព្រឹត្តិអំពើមិនសុចរិតធម្មតា			៣០ថ្ងៃ
-ការប៉ុនប៉ងប្រព្រឹត្តសកម្មភាពមិនសុចរិត			៣០ថ្ងៃ
-ការបើក ឬប៉ុនប៉ងដោយបើកបង្ខំទូណាមួយបន្ទប់ណាមួយ ឬកន្លែងណាមួយ ដែលមាន សំភារៈ			៣០ថ្ងៃ
-ការរុករើរកក្នុងទូ ឬប្រអប់តូចៗ ឬគ្រឿងសំ ភារៈផ្ទាល់ខ្លួនរបស់អ្នកដទៃ			២០ថ្ងៃ
-ការយកចេញដោយគ្មានការអនុញ្ញាតនូវកូនសោរទូពីបន្ទប់ណាមួយ ឬកន្លែង ណាមួយ ដែលគ្មានសំភារៈផ្សេងៗ			៣០ថ្ងៃ
-ការល្បួងលួងលោមយកខោអាវរបស់គេ តែ គ្មានបំណងយកជារបស់ផ្ទាល់ខ្លួន	X		
-ការកែបន្លំតម្លៃដែលបានកំណត់អោយ			១៥ថ្ងៃ

ការមិនពិត និងការក្លែងក្លាយ			
-ការធ្វើការកាន់កាប់ ដោយមិនត្រឹមត្រូវនៅក្នុងកិច្ចការរបស់គណនេយ្យ			៦០ថ្ងៃ
-ការរៀបចំកាន់កាប់មិនត្រឹមត្រូវ នូវឯកសារ			៦០ថ្ងៃ
-ការធ្វេសប្រហែស ក្នុងការកាន់កាប់គណនេយ្យ			៣០ថ្ងៃ
-ការធ្វេសប្រហែស ក្នុងការរៀបចំឯកសារ			៣០ថ្ងៃ
-ការរៀបចំកាន់កាប់ថវិកាជាតិមិនត្រឹមត្រូវ			៣០ថ្ងៃ
-ការរាយការណ៍មិនជាក់ស្តែង នៅពេលត្រួតពិនិត្យ ឬអង្កេត			៤៥ថ្ងៃ
-ការនិយាយកុហកក្នុងក្រសួង ឬរាយការណ៍ខុស ដោយចេតនា ឬឲ្យប្រាស់-លាស់			១៥ថ្ងៃ
-ការបោកបញ្ឆោត ឬការប៉ុនប៉ងបោកបញ្ឆោត លើសេចក្តីទុកចិត្តរបស់អ្នកដឹកនាំ			២០ថ្ងៃ
-ការបោកបញ្ឆោត លើសេចក្តីទុកចិត្តរបស់មិត្តភក្តិ	X		
-ការកាន់កាប់ច្បាប់អនុញ្ញាតអោយឈប់សំរាក ដោយបន្លំ ឬក្លែងក្លាយច្បាប់ឈប់សំរាក			១៥ថ្ងៃ
-ការអនុញ្ញាត ឬចុះហត្ថលេខាលើលិខិតច្បាប់ ដោយគ្មានសិទ្ធិ និងចុះហត្ថលេខា			០៨ថ្ងៃ

-ការប្រើប្រាស់ដោយបន្លំ នូវត្រា ក្រដាស់ស្នាម ឬក្រដាស់ពុម្ពរបស់ក្រសួង -ការផ្តល់អាស័យដ្ឋានមិនពិតនៅពេលចេញទៅច្បាប់ -ការបង្ហាញអត្តសញ្ញាណប័ណ្ណដោយប្រើឈ្មោះខុស -ការបន្លំចំនួនទាហានពិត ដោយគិតទុកជាមុន	X		១៥ថ្ងៃ ១៥ថ្ងៃ ២០ថ្ងៃ

ឆាយឆាហានរេខ

ប្រភេទទី ៣

កំហុសផ្ទុយនឹងវិន័យយោធា

ហេតុផល	ទោសកំហុសដែលត្រូវដាក់		
	ការព្រមាន	ការស្តីបន្ទោស	ការស្តីបន្ទោសដោយលាយល័ក្ខណអក្សរ ឬការផ្អាកមុខដំណែង
ការប៉ះពាល់ដល់អព្យាក្រឹតភាពរបស់កងទ័ព -ការប៉ះពាល់ដល់អព្យាក្រឹតភាពរបស់កងទ័ព ការរឹងរូស មិនចំណុះ -ការបានដឹកនាំអ្នកក្រោមបង្គាប់			 ៦០ថ្ងៃ ៦០ថ្ងៃ

អោយតវ៉ា ដោយរួមគ្នាជាច្រើន អោយប្រឆាំងនឹងមុខងារ			
-ការបានដឹកនាំមិត្តភក្តិឯទៀត ដោយស្រុះស្រួលគ្នា ដើម្បីសុំ ឬធ្វើបាតុកម្មប្រឆាំងនឹងមុខការ			៤៥ថ្ងៃ
-ការបានទៅរួបរួមគ្នា នៅក្នុងការតវ៉ានឹងការ បះបោរប្រឆាំងនឹងមុខការ			៤៥ថ្ងៃ
-ការតវ៉ាដោយសំអាងអ្វីមួយ ដែលមិនត្រឹមត្រូវ ដោយបានគិតទុកជាមុន			៤៥ថ្ងៃ
-ការសរសេរទៅថ្នាក់លើ ដោយមិនគោរពតាម ឋានានុក្រម			១០ថ្ងៃ
ការមិនគោរពតាម			
-ការមិនគោរពតាមដោយជាក់លាក់នូវបទបញ្ជា			៦០ថ្ងៃ
-ការមិនព្រមអនុវត្តនូវបទបញ្ជារហូតមាន អន្តរាគមន៍ពីថ្នាក់លើ			១៥ថ្ងៃ
-ការមិនគោរពតាមនូវបង្គាប់ជាដាច់ខាតលើកទី១ម្តងៗ			១០ថ្ងៃ
-ការមិនគោរពនូវបទបញ្ជាដោយចេតនា			៣០ថ្ងៃ
-ការអនុវត្តតាមបញ្ជាដោយយឺតយ៉ាវ		X	
-ការមិនសម្រេបតាមនូវបញ្ជាដែលបានទទួល		X	
-ការមិនគោរពគ្រូបង្ហាត់			១០ថ្ងៃ
ការរំលោភអំណាច			
-ការធ្វើទុក្ខបុកម្នេញយ៉ាងធ្ងន់ធ្ងរដល់អ្នកក្រោមបង្គាប់ ឬមនុស្សណាមួយ			៦០ថ្ងៃ

ក្រោម ឱវាទរបស់ខ្លួន -ការប្រព្រឹត្តិអំពើគំរោះគំរើយដល់អ្នកក្រោមបង្គាប់ ឬជនណាមួយនៅក្រោមឱវាទរបស់ខ្លួន -ការធ្វើបាបទៅលើអ្នកក្រោមបង្គាប់ ឬក្រោម ឱវាទ -ការរំលោភសិទ្ធិរបស់អ្នកនៅក្រោមបង្គាប់ ការប្រមាថ និងបំពានលើរូបរាងកាយ -ការប្រមាថមើលងាយដល់ទង់ជាតិ ឬកងទ័ព -ការភ្លេចគោរពទង់ជាតិ -ការរំលោភ ការកំហែង ការច្រងេងច្រងាង ការឆ្លើយត្រគោះបោះបោកដល់អ្នកមានបណ្ដាស័ក្តិ ធំជាង -ការបណ្ដោយអោយនរណាម្នាក់ធ្វើទុក្ខបុកម្នេញ -ការខ្វះខាតក្នុងការគោរព និងអាកប្បកិរិយា ច្រងេងច្រងាងដល់អ្នកមានបណ្ដាស័ក្តិធំជាង -ការគំរាមកំហែង ដើម្បីនឹងដាក់ពាក្យតវ៉ា -ការគំរោះគំរើយដល់អ្នកយាម ឬភ្នាក់ងារមាន សមត្ថកិច្ច			៤០ថ្ងៃ ២០ថ្ងៃ ២០ថ្ងៃ ៦០ថ្ងៃ ១៥ថ្ងៃ ៦០ថ្ងៃ ៣០ថ្ងៃ ១០ថ្ងៃ ៦០ថ្ងៃ

នាយទាហានរង

ប្រភេទទី ៤

ការខ្វះខាតក្នុងការអនុវត្តន៍វិជ្ជាជីវៈ

ហេតុផល	ទោសកំហុសដែលត្រូវដាក់		
	ការព្រមាន	ការស្តីបន្ទោស	ការស្តីបន្ទោសដោយលាយល័ក្ខណ៍អក្សរ ឬការផ្អាកមុខដំណែង
-ការខ្វះខាតយ៉ាងធ្ងន់ធ្ងរ ចំពោះក្បួនច្បាប់ នៃការងារ			៦០ថ្ងៃ
បទល្មើសចំពោះសេចក្តីបង្គាប់អាជ្ញា			
-ការប្រព្រឹត្តិបទល្មើស ដោយគិតទុកជាមុន(ដោយចេតនា) ក្នុងវិន័យយោធា ឬក្នុងសេចក្តីបង្គាប់			៣០ថ្ងៃ
-ការមិនស្តាប់បង្គាប់ ការបង្គាប់របស់អ្នកយាម			៣០ថ្ងៃ
-ការមិនបានប្រព្រឹត្តិតាមវិន័យយោធា និង សេចក្តី បង្គាប់ការ			២០ថ្ងៃ
-ការប៉ុនប៉ងប្រព្រឹត្តបទល្មើស ចំពោះវិន័យយោធា ឬសេចក្តីបង្គាប់ការ		X	
-ការធ្វើវិយោគក្នុងមុខងារ ឬការទទួលខុសត្រូវ ឬការបណ្តោយអោយមានការប្រព្រឹត្តិបទល្មើស ចំពោះ វិន័យកងទ័ព រាល់បទបញ្ជា ឬរាល់សេចក្តីបង្គាប់			៤៥ថ្ងៃ
-ការមិនប្រព្រឹត្តិតាមកិច្ចសន្យា បញ្ញត្តិ [illegible]		X	

ចក្តី បង្គាប់ការនិងវិន័យ យ៉ាងល្អិតល្អន់ (វិន័យពិសេស នៅក្នុងធរមានបញ្ញត្តិក្នុងកងឯកភាព ឬក្នុងជួរកង-ទ័ព)			
-ការធ្វេសប្រហែស ក្នុងការប្រព្រឹត្តិតាមសេចក្តី បង្គាប់ ឬបញ្ញត្តិណាមួយ		X	
ការបោះបង់មូលដ្ឋាន			
-ការចាកចេញពីមូលដ្ឋាន ដោយគ្មានសេចក្តីអនុញ្ញាត			៦០ថ្ងៃ
-ការមិនទៅដល់មូលដ្ឋាន ដែលបានកំណត់ អោយទៅបំរើការងារ			៦០ថ្ងៃ
-ការអវត្តមានតែមួយស្របក់ នៅក្នុងកន្លែង បំពេញការងារ			៤៥ថ្ងៃ
-ការអវត្តមានតែមួយស្របក់ ដោយមិនចេញឆ្ងាយពីមូលដ្ឋាន	X		
-ការបោះបង់ចោលកន្លែងហ្វឹកហាត់ ឬកិច្ចការ ផ្សេងៗ ដែលបានកំណត់អោយ			២០ថ្ងៃ
-ការដែលនៅក្នុងករណីជំនួសមុខការ ដោយគ្មាន ការអនុញ្ញាត			១៥ថ្ងៃ
-ការដែលនាយរថយន្ត ឬអ្នកបើកបរបានចាក ចេញពីរថយន្តដោយឥតច្បាប់ ឬផ្ញើទុកនឹងគេ ដោយគ្មានច្បាប់អនុញ្ញាតនូវរថយន្ត ឬទុកក្តាររបស់ខ្លួនកាន់កាប់			២០ថ្ងៃ
-ការចាកចេញពីរថយន្តរយៈពេលខ្លី (មួយស្របក់) ដោយគ្មានច្បាប់ អនុ-		X	

ញ្ញាត ការខ្វះខាតនៅក្នុងកិច្ចការយាមកាម ក្នុងពេលយប់ និងប្រចាំការ			
-ការធ្វេសប្រហែស ក្នុងកិច្ចការយាមកាម កិច្ចការ ត្រួតពិនិត្យ			៦០ថ្ងៃ
-ការដេកក្នុងពេលយាមកាម និងការត្រួតពិនិត្យ			២០ថ្ងៃ
-កំហុសយ៉ាងធ្ងន់ទៅលើការត្រួតពិនិត្យពួក ប្រចាំការ-នាយប្រចាំសប្តាហ៍ នាយយាមកាម នាយត្រួតពិនិត្យ១៥នាទីម្តង និងយាមល្បាត ក្រុមទាហាន ដែលរៀបចំជាស្រេចនៅពេលចេញ ប្រតិបត្តិការ			២០ថ្ងៃ
-ការមិនដើរល្បាតតាមស្ថានភាពដែលកំណត់អោយ			២០ថ្ងៃ
-ការដើរចោលទីកន្លែង ក្នុងកំឡុងពេលយាម កាម១៥នាទីម្តងដោយគ្មានអ្នកជំនួស			១០ថ្ងៃ
-ការមិនងើបពីដេកដល់ពេលវេលាដែលត្រូវ យាមកាម			១០ថ្ងៃ
-ការមកដោយយឺតយ៉ាវក្នុងពេលយាមកាម	X		
ការប្រព្រឹត្តិបទល្មើស មកមិនទាន់ពេលវេលា នៅពេលបំពេញមុខងារ			
-ការមកមិនទាន់ពេលធ្វើការ ឬចេញពីធ្វើការ មុនម៉ោង			០៤ថ្ងៃ
-ការអនុវត្តន៏ការងារមិនល្អដោយ			៤៥ថ្ងៃ

ចេតនា -ការមានបំណងមិនល្អ ជានិច្ចកាលនៅក្នុងមុខងារ -ការមិនបានព្យាបាលខ្លួន នៅពេលមានជម្ងឺ ដើម្បីគេចវេះពីការងារ -ការដែល បង្ហាញខ្លួន នៅពេលទៅមន្ទីរពេទ្យ ដោយសាមីខ្លួនមានជម្ងឺ ដើម្បីគេចវេះពីការងារ -ការមិនបានទៅ នៅពេលចេញទៅហ្វឹកហ្វឺន -ការមិនបានទៅបង្ហាញខ្លួន នៅពេលត្រួតពិនិត្យ		X	៣០ថ្ងៃ ២០ថ្ងៃ ២០ថ្ងៃ ០៨ថ្ងៃ
ការប្រព្រឹត្តិទូវក្បួនខ្នាត សន្តិសុខ និងសេចក្តីបង្គាប់ជាដាច់ខាត នៃអនាម័យ -ការខ្វះខាត និងអនុវត្តក្បួនខ្នាត សន្តិ-សុខ -ការខ្វះខាត និងអនុវត្តក្បួនខ្នាតអនា-ម័យ -ការដក់បារី ធ្វើអោយភ្លើងឆេះនៅជិតឃ្លាំងគ្រាប់ ឃ្លាំងសាំង និងឃ្លាំងដែលមានគ្រឿងផ្ទុះ -ការលេងអាវុធ លេងគ្រាប់ដោយគ្មានច្បាប់ -ការមិនអនុវត្តនីតាមសេចក្តីបង្គាប់របស់ពេទ្យ -ការចោលកំទេច ឬ កាកអ្វីក្រៅពី	X X		៣០ថ្ងៃ ១៥ថ្ងៃ ៣០ថ្ងៃ ២០ថ្ងៃ

កន្លែង បានកំហិតអោយ			
-ការនាំចូលនូវអាវុធផ្ទាល់ខ្លួន ក្នុងបរិ-វេណ ទាហានដោយគ្មានការអនុញ្ញាត			៣០ថ្ងៃ
-ការកាន់អាវុធ គ្រាប់បែក គ្រឿងផ្ទុះ ដោយខុសច្បាប់			៣០ថ្ងៃ
-ការកែប្រែសំភារៈសព្វាវុធ គ្រាប់រំសេវ ទាំងឡាយ ដោយគ្មានច្បាប់			៣០ថ្ងៃ
-ការឃោគយល់ជួយណែនាំអោយ ប្រព្រឹត្តនូវ គ្រឿងញៀន			៦០ថ្ងៃ
-ការប្រើប្រាស់គ្រឿងញៀន			៣០ថ្ងៃ
-ការនាំចូលដោយគ្មានច្បាប់អនុញ្ញាត ក្នុងបរិ វេណទាហាន មានគ្រឿងញៀន មានជាតិស្រា ហើយនិងគ្រឿងផ្ទុះ			៣០ថ្ងៃ
-ការញុះញង់អោយប្រើគ្រឿងស្រវឹង ដោយហួសហេតុ			៣០ថ្ងៃ
-ការប្រព្រឹត្តិមិនស្អាតស្អំ			១៥ថ្ងៃ
-ការចេញចូលក្នុងកន្លែងហាមឃាត់			០៨ថ្ងៃ
-បទល្មើសនឹងច្បាប់ក្នុងការជក់បារី			១០ថ្ងៃ
-ការហាលខោអាវមិនតាមច្បាប់ទម្លាប់	X		
-ការដេកខុសកន្លែង ដែលបានកំណត់ អោយ	X		
-ការងូតទឹកមិនត្រឹមត្រូវ	X		
-ការមិនថែទាំសំភារៈ និងលុយកាក់ ផ្ទាល់ខ្លួន	X		
ការហាមឃាត់ផ្សេងៗ			
-ការមិនអនុវត្តន៏តាមក្បួនច្បាប់ នៅ ពេលដែល យើងទៅសំរាកនៅប្រទេស			១០ថ្ងៃ

ក្រៅ -ការនាំមនុស្សក្រៅចូលមក ក្នុងបរិ-វេណយោធា			២០ថ្ងៃ
ការប្រើប្រាស់ ដោយគ្មានសណ្តាប់ធ្នាប់ យានជំនិះ ឬសំភារៈយោធា -ការប្រើប្រាស់ដោយគ្មានច្បាប់ ហើយគ្មានសណ្តាប់ធ្នាប់នូវយានជំនិះ និងសំភារៈយោធា			៤៥ថ្ងៃ
-ការបង្វែងជានដោយចេតនា នូវគោលដៅដែល ត្រូវទៅ			១០ថ្ងៃ
-ការដឹកនាំជនស៊ីវិលតាមរថយន្ត យោ-ធា ដោយគ្មានច្បាប់អនុញ្ញាត			២០ថ្ងៃ
-ការដឹកនាំយោធា និងសំភារៈផ្សេងៗ ដោយ គ្មានច្បាប់អនុញ្ញាត			១៥ថ្ងៃ
-ការប្រើប្រាស់ដោយគ្មានច្បាប់ នូវសំភារៈ រាជការសំរាប់ប្រយោជន៍ផ្ទាល់ខ្លួន			៣០ថ្ងៃ
បទល្មើសនឹងច្បាប់ ក្នុងកិច្ចការពារការសម្ងាត់ -ការមិនចេះលាក់នូវអាថិកំបាំង ដោយវោហារ ឬសរសេរដែលបណ្តាលអោយមានវិបត្តិយ៉ាងធ្ងន់			៤៥ថ្ងៃ
-ការទាក់ទងជាមួយមនុស្សដែលគ្មានសមត្ថភាព ដែលដឹងការសម្ងាត់			៤៥ថ្ងៃ
-ការធ្វើអោយបាត់បង់ឯកសារ			២០ថ្ងៃ
-ការកាន់កាប់ឯកសារដោយគ្មានច្បាប់អនុញ្ញាត			

-ការធ្វេសប្រហែសក្នុងការរាយការណ៏ពីការ បាត់បង់ខូចខាតសំភារៈ គ្រោះ-ថ្នាក់ក្នុងពេល ដែលយើងគ្រប់គ្រង			២៥ថ្ងៃ

នាយធាហានរង

ប្រភេទទី ៥

កំហុសនឹងការធ្វេសប្រហែសនៅក្នុងមុខងារ

ហេតុផល	កំហុសដែលត្រូវដាក់		
	ការព្រមាន	ការស្តីបន្ទោស	ការស្តីបន្ទោសដោយលាយល័ក្ខណអក្សរ ឬការផ្អាកមុខដំណែង
-ការមានកំហុសជាទម្ងន់ដោយធ្វេសប្រហែស នៅក្នុងមុខងារដែលបណ្តាលអោយមានគ្រោះ-ថ្នាក់ដល់អាយុជីវិត ឬខូចខាតយ៉ាងធ្ងន់ធ្ងរដល់ សំភារៈ			៦០ថ្ងៃ
-ការបាត់បង់សំភារៈ ឬឯកសារផ្សេងៗ			៣០ថ្ងៃ
-ការមិនរាយការណ៏នៅពេលបាត់អត្តសញ្ញាណប័ណ្ណ			១៥ថ្ងៃ

នាយធាហានរ៦

ប្រភេទធនី ៦

កំហុសប៉ះពាល់ដល់កិរិយាមារយាទល្អ

(កំហុសអាកប្បកិរិយា និងឯកសណ្ឋាន)

ហេតុផល	ទោសកំហុសដែលត្រូវដាក់		
	ការព្រមាន	ការស្តីបន្ទោស	ការស្តីបន្ទោសដោយលាយល័ក្ខណអក្សរ ឬការផ្អាកមុខដំណែង
-ការប៉ះពាល់យ៉ាងធ្ងន់ដល់កិរិយាមារយាទ			៦០ថ្ងៃ
បទល្មើសក្នុងការស្លៀកពាក់ឯក-សណ្ឋាន			
-ការស្លៀកពាក់ឯកសណ្ឋានផ្ទុយនឹងអនុក្រឹត្យ នៅក្នុងបរិវេណអង្គភាពទ័ព			២០ថ្ងៃ
-ការស្លៀកពាក់ឯកសណ្ឋាន ផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៅក្នុង ឬក្បែរ បរិ-វេណកងទ័ព			១៥ថ្ងៃ
-ការស្លៀកពាក់ឯកសណ្ឋានផ្តេស-ផ្តាស់ គគ្រិច នៅក្រៅបរិវេណអង្គភាព			០៤ថ្ងៃ
-ការស្លៀកពាក់ឯកសណ្ឋានផ្តេសផ្តាស់ គគ្រិច នៅក្នុង ឬក្បែរបរិវេណអង្គភាព			០៤ថ្ងៃ
-ការដែលមិនស្លៀកពាក់សមស្របតាមបទប្បញ្ញត្តិ	X		
-ការប្រើប្រាស់ឯកសណ្ឋានស៊ីវិល		X	

ហ៊ឹហារហួសហេតុ ក្នុងបរិវេណយោធា			
កំហុសក្នុងការប្រព្រឹត្ត			
-ការប្រព្រឹត្តនូវបាបកម្ម			៤៥ថ្ងៃ
-ការបង្កហេតុធ្វើឱ្យបាត់សណ្តាប់ធ្នាប់ក្នុងពេលបំពេញការងារ ឬចេញប្រតិបត្តិការ			៣០ថ្ងៃ
-ការបង្កហេតុ ឬប្រព្រឹត្តិបាបកម្មនៅក្រៅបរិវេណកងឯកភាព			២០ថ្ងៃ
-ការបង្កហេតុ ឬប្រព្រឹត្តិបាបកម្មនៅក្នុងបរិវេណ កងឯកភាព			២០ថ្ងៃ
-ការស្រវឹងស្រាដែលនាំអោយរាំងស្ទះក្នុងកិច្ចការ			៣០ថ្ងៃ
-ការស្រវឹងស្រា នៅពេលបំពេញកិច្ចការ			២០ថ្ងៃ
-ការស្រវឹងស្រា ប្រព្រឹត្តិបាបកម្មនៅក្រៅបរិវេណ កងឯកភាព			៣០ថ្ងៃ
-ការធ្វើទុក្ខបុកម្នេញ ចំពោះមិត្តភក្តិ			៦០ថ្ងៃ
-ការធ្វើទុក្ខបុកម្នេញធម្មតា			៣០ថ្ងៃ
-ការមិនបានធ្វើអន្តរាគមន៍ នៅពេលឃើញគេ ធ្វើទុកបុកម្នេញអ្នកដទៃ			៣០ថ្ងៃ
-ការប្រព្រឹត្តិអំពើឃោរឃៅ ធ្វើអោយបាក់មុខមាត់ ដោយអាម៉ាស់ទៅលើមិត្តភ័ក្តិ			៣០ថ្ងៃ
-ការរួមគំនិត ធ្វើអោយអាម៉ាស់ ឬបាក់ មុខមាត់			៣០ថ្ងៃ
-ការដាល់តប់ ឬឈ្លោះប្រកែកគ្នា			១៥ថ្ងៃ
-ការផលិត ឬកែច្នៃសំរាប់អាជីវកម្ម			៦០ថ្ងៃ

ទិញលក់ អាវុធគ្រាប់រំសេវ ជាតិផ្ទុះផ្សេងៗ			

តារាងអត្រាដាក់ទណ្ឌកម្ម

នាយទាហាន

ប្រភេទទី ១

កំហុសដែលលំអៀង ដើម្បីគេចអោយផុតពីកាតព្វកិច្ចយោធា

ហេតុផល	ទោសកំហុសដែលត្រូវដាក់		
	ការព្រមាន	ការស្តីបន្ទោស	ការស្តីបន្ទោសដោយលាយល័ក្ខណអក្សរ ឬការផ្អាកមុខដំណែង
អំពើឈ្លានពានដោយចេតនា			
-ការធ្វើអោយរបួសខ្លួនឯង ដើម្បីគេចវេះការងារ ឬពេលដែលកងឯកភាពនោះចេញ ប្រតិបត្តិការសឹក			៦០ថ្ងៃ
-ការធ្វើអោយរបួសខ្លួនឯង ដើម្បីគេចវេះនៅពេលចុះទៅបំពេញមុខការ ដែលបានទទួលបញ្ជាហើយ			៣០ថ្ងៃ
-ការប្រព្រឹត្តិអំពើឃោរឃៅដោយចេតនា			៦០ថ្ងៃ
អវត្តមានការមិនបង្ហាញខ្លួន			
-ការមិនឃើញមកដោយស្ម័គ្រចិត្ត ឬដោយធ្វេសប្រហែសធ្ងន់ នៅពេលចេញទៅបំពេញបេសកកម្ម			៦០ថ្ងៃ
-ការមិនឃើញមក នៅពេលចេញដំណើរទៅហ្វឹកហាត់ ឬសមយុទ្ធ			៣០ថ្ងៃ
-ការមិនឃើញមក នៅពេលចេញដំណើររបស់			៣០ថ្ងៃ

កងឯកភាព ឬចេញដំណើរទៅបេសកកម្ម			
-ការអវត្តមានហួសពី ០៦ថ្ងៃ			៤៥ថ្ងៃ
-ការអវត្តមានពី០១ថ្ងៃទៅ០៦ថ្ងៃ			៤៥ថ្ងៃ
-ការអវត្តមាន២៤ម៉ោង			២០ថ្ងៃ
-ការអវត្តមាន១២ម៉ោង			០៥ថ្ងៃ
-ការអវត្តមាន០២ម៉ោង			
-ការមិនបានប្រាប់កងឯកភាពខ្លួន នៅពេលដែល ចេញទៅធ្វើការមិនទាន់ពេល ដោយដឹងជាមុន	X		
-ការទៅមិនទាន់ពេល ដើម្បីទៅជាមួយកងឯកភាពខ្លួន ដែលទៅធ្វើកិច្ចការក្រៅបន្ទាយ	X		
-ការដោះដៃ ឬគេចមុខការ ដែលត្រូវធ្វើ			៣០ថ្ងៃ
-ការគេចខ្លួន ឬប្រាថ្នាគេចខ្លួន ដែលឆែកឆេរចេញចូលបរិវេណយោធា	X		

<u>កំណត់សំគាល់</u> :

ទាហានថ្មី ០៣ខែរត់ចោលជួរ គ្មានទោសពៃរ៍ឡើយ។ ហួសពី០៦ខែ ទាហានណាបាត់មុខ ២៤ម៉ោងក្នុងពេលសង្គ្រាម ត្រូវវាយទូរលេខរកសាមីខ្លួន។

បាត់មុខហួសពី១៥ថ្ងៃ ត្រូវចាត់ទុកជារត់ចោលជួរ ហើយផ្ញើសំណុំលិខិតទៅតុលាការ អំពីការរត់ចោលជួរ ទោះចាប់បាន ឬមិនបានក៏ដោយ។

ឆាយឆាហាន

ប្រភេទទី ២

កំហុសផ្ទុយនឹងកិត្តិយស សេចក្តីនៀវត្រង់ ឬកាតព្វកិច្ចយោធា

ហេតុផល	ទោសកំហុសដែលត្រូវដាក់		
	ការព្រមាន	ការស្តីបន្ទោស	ការស្តីបន្ទោសដោយលាយល័ក្ខណអក្សរ ឬការផ្អាកមុខដំណែង
-ការខ្វះខាតយ៉ាងធ្ងន់ចំពោះកាតព្វកិច្ច និងការធានាខុសត្រូវ នៅពេលប្រយុទ្ធ			៦០ថ្ងៃ
-ការអោយបញ្ជាដោយល្មើសច្បាប់ផ្ទុយនឹងច្បាប់			៦០ថ្ងៃ
-ការបំពេញអំពើអ្វីមួយ ដែលល្មើសនឹងច្បាប់ ការរួមគំនិត ការញុះញង់ប្រព្រឹត្តនូវការច្របូកច្របល់			៦០ថ្ងៃ
-ការប៉ះពាល់យ៉ាងធ្ងន់ដល់រាជការពេញច្បាប់			៦០ថ្ងៃ
-ការប៉ះពាល់យ៉ាងធ្ងន់ដល់សីលធម៌កងទ័ព			៦០ថ្ងៃ
-ការបង្ក ឬញុះញង់អោយធ្វើបាតុកម្ម ការសុំ និងការតវ៉ា ដោយរួមគ្នា ជាច្រើន			៦០ថ្ងៃ
-ការឃោសនា ប្រឆាំងនឹងយោធា នឹងជាតិ			៦០ថ្ងៃ
-កាប៉ុនប៉ងបង្វែងដានទាហានម្នាក់ អោយចាកផុតពីករណីយកិច្ចរបស់ខ្លួន			៤៥ថ្ងៃ
-ការខំប្រឹងបង្វែងដានមិត្តរួមអាវុធម្នាក់ អោយចេញផុតពីមុខការ និងករណីយកិច្ច			៣០ថ្ងៃ
-ការមិនប្រឹងប្រែងជួយកិច្ចការរាជការណាមួយ			១០ថ្ងៃ
-ការមិនជួយធ្វើអន្តរាគមន៏នូវចំពោះស្ថានការណ៏ដែលត្រូវការអ្នកផ្តើមគំនិត			២០ថ្ងៃ

កំហុសដែលប៉ះពាល់ដល់កិត្តិយស ល្បីឈ្មោះ របស់កងទ័ព			
-ការបញ្ចេញអាកប្បកិរិយា ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ កេរ្តិ៍ឈ្មោះកងទ័ព			៦០ថ្ងៃ
-ការមិនគោរព និងមិនបញ្ចេញមតិ ក្នុងការសរសេរ និងពាក្យសំដី			៣០ថ្ងៃ
ការបំផ្លាញ ឬបាត់បង់ដោយចេតនា			
-ការវាយបំបែកដោយចេតនា ទៅលើសំភារៈនៅហ្នឹងកន្លែង ឬបន្ទប់ណាមួយ			៦០ថ្ងៃ
-ការធ្វើអោយបាត់បង់សំភារៈទាំងឡាយ ដោយចេតនា			៦០ថ្ងៃ
-ការធ្វើអោយខូចខាតដោយចេតនាកន្លែង ឬបន្ទប់ណាមួយ នូវសំភារៈតូចៗ និងសំលៀកបំពាក់ទាហាន			៣០ថ្ងៃ
-ការខ្ជះខ្ជាយដោយចេតនា ទៅលើគ្រឿងឧបភោគ បរិភោគ			១០ថ្ងៃ
ការកែបំបាត់			
-ការយកមកធ្វើជារបស់ផ្ទាល់ខ្លួន នូវសព្វាវុធសំភារៈ និងគ្រឿងឧបករណ៍ផ្សេងៗរបស់រាជការ			១៥ថ្ងៃ
-ការលក់គ្រឿងសំភារៈតូចតាច និងគ្រឿងឧបភោគ បរិភោគយោធា			៣០ថ្ងៃ
-យោធបរិក្ខារ-បរិក្ខារពេទ្យ			៦០ថ្ងៃ
អំពើសុចរិត			
-ការប្រព្រឹត្តិអំពើមិនសុចរិតយ៉ាងធ្ងន់ធ្ងរ			៦០ថ្ងៃ
-ការប្រព្រឹត្តិអំពើមិនសុចរិតធម្មតា			៣០ថ្ងៃ
-ការប៉ុនប៉ងប្រព្រឹត្តនូវសកម្មភាពមិនសុច្ចរិត			៣០ថ្ងៃ
-ការបើក ឬប៉ុនប៉ងដោយបើកបង្ខំទូណាមួយ			៣០ថ្ងៃ

បន្ទប់ណាមួយ ឬកន្លែងណាមួយ ដែលមានសំភារៈ			
-ការរុករើរកក្នុងទូ ឬប្រអប់តូចៗ ឬគ្រឿងសំភារៈផ្ទាល់ខ្លួនរបស់អ្នកដទៃ			២០ថ្ងៃ
-ការយកចេញដោយគ្មានការអនុញ្ញាត នូវកូនសោរទូរពីបន្ទប់ណាមួយ ឬកន្លែងណាមួយ ដែលមានសំភារៈផ្សេងៗ			៣០ថ្ងៃ
-ការល្បងលួងលោមយកខោអាវរបស់គេ តែគ្មាន បំណងយកជារបស់ផ្ទាល់ខ្លួន	X		
-ការកែបន្លំតម្លៃដែលបានកំណត់អោយ			១៥ថ្ងៃ
ការមិនពិត និងការក្លែងក្លាយ			
-ការធ្វើការកាន់កាប់ ដោយមិនត្រឹមត្រូវ នៅក្នុងកិច្ចការរបស់គណនេយ្យ			៦០ថ្ងៃ
-ការរៀបចំកាន់កាប់មិនត្រឹមត្រូវ នូវឯកសារ			៦០ថ្ងៃ
-ការធ្វេសប្រហែស ក្នុងការកាន់កាប់គណនេយ្យ			៣០ថ្ងៃ
-ការធ្វេសប្រហែស ក្នុងការរៀបចំឯកសារ			៣០ថ្ងៃ
-ការរៀបចំកាន់កាប់ថវិកាជាតិមិនត្រឹមត្រូវ			៣០ថ្ងៃ
-ការរាយការណ៍មិនជាក់ស្តែង នៅពេលត្រួតពិនិត្យ ឬអង្កេត			៦០ថ្ងៃ
-ការនិយាយកុហក់ក្នុងក្រសួង ឬរាយការណ៍ខុស ដោយចេតនា ឬមិនច្បាស់លាស់			៣០ថ្ងៃ
-ការបោកបញ្ឆោត ឬការប៉ុនប៉ងបោកបញ្ឆោតលើសេចក្ដីទុកចិត្តរបស់អ្នកដឹកនាំ			៣០ថ្ងៃ
-ការបោកបញ្ឆោត លើសេចក្ដីទុកចិត្តរបស់មិត្តភក្តិ	X		
-ការកាន់កាប់ច្បាប់អនុញ្ញាតអោយឈប់សំរាក ដោយបន្លំ ឬក្លែងក្លាយច្បាប់ឈប់សំរាក			២០ថ្ងៃ

-ការអនុញ្ញាត ឬចុះហត្ថលេខាលើលិខិតច្បាប់ ដោយគ្មានសិទ្ធិ និងចុះហត្ថលេខា			០៨ថ្ងៃ
-ការប្រើប្រាស់ដោយបន្លំ នូវត្រា ក្រដាស់ស្លាក ឬក្រដាស់ពុម្ពរបស់ក្រសួង			២០ថ្ងៃ
-ការផ្តល់អាស័យដ្ឋានមិនពិតនៅពេលចេញទៅច្បាប់	X		
-ការបង្ហាញអត្តសញ្ញាណប័ណ្ណដោយប្រើឈ្មោះខុស			២០ថ្ងៃ
-ការបន្លំចំនួនទាហានពិត ដោយគិតទុកជាមុន នៅពេលប្រជុំជួរ			៣០ថ្ងៃ

នាយទាហាន

ប្រភេទទី ៣

កំហុសផ្ទុយនឹងវិន័យយោធា

ហេតុផល	ទោសកំហុសដែលត្រូវដាក់		
	ការព្រមាន	ការស្តីបន្ទោស	ការស្តីបន្ទោសដោយលាយល័ក្ខណអក្សរ ឬការផ្អាកមុខដំណែង
ការប៉ះពាល់ដល់អព្យាក្រឹតភាពរបស់កងទ័ព			
-ការប៉ះពាល់ដល់អព្យាក្រឹតភាពរបស់កងទ័ព			៦០ថ្ងៃ
ការរឹងរូស មិនចំណុះ			
-ការបានដឹកនាំអ្នកក្រោមបង្គាប់ អោយតវ៉ា ដោយរួមគ្នាជាច្រើនអោយប្រឆាំងនឹងមុខងារ			៦០ថ្ងៃ
-ការបានដឹកនាំមិត្តភ័ក្តិឯទៀត ដោយស្រុះស្រួលគ្នា ដើម្បីសុំ ឬធ្វើបាតុកម្មប្រឆាំងនឹងមុខការ			៦០ថ្ងៃ

-ការបានទៅរូបរួមគ្នា នៅក្នុងការតវ៉ា និងការបះបោរប្រឆាំងនឹងមុខការ			៣០ថ្ងៃ
-ការតវ៉ាដោយសំអាងទៅអ្វីមួយ ដែលមិនត្រឹមត្រូវ ដោយបានគិតទុកជាមុន			៦០ថ្ងៃ
-ការសរសេរទៅថ្នាក់លើ ដោយមិនគោរពតាមឋានានុក្រម			២០ថ្ងៃ
-ការរៀបអាពាហ៍ពិពាហ៍ ដែលមិនបានសុំការអនុញ្ញាតជាមុន (ពីរដ្ឋមន្ត្រីក្រសួងការពារជាតិ)			៣០ថ្ងៃ
ការមិនគោរពតាម			
-ការមិនគោរពតាមដោយជាក់លាក់នូវបទបញ្ជា			៦០ថ្ងៃ
-ការមិនព្រមអនុវត្តនូវបញ្ជា រហូតមានអន្តរាគមន៍ពីថ្នាក់លើ			២០ថ្ងៃ
-ការមិនគោរពតាមនូវបង្គាប់ជាដាច់ខាតលើកទី១ម្តង ។			២០ថ្ងៃ
-ការមិនគោរពនូវបទបញ្ជាដោយចេតនា	X		
-ការអនុវត្តន៍តាមបទបញ្ជាដោយយឺតយ៉ាវ	X		
-ការមិនសម្រេចតាមនូវបញ្ជាដែលបានទទួល	X		
-ការមិនគោរពគ្រូបង្ហាត់			១០ថ្ងៃ
ការរំលោភអំណាច			
-ការធ្វើទុក្ខបុកម្នេញយ៉ាងធ្ងន់ធ្ងរដល់អ្នកក្រោមបង្គាប់ ឬមនុស្សណាមួយក្រោមឱវាទរបស់ខ្លួន			៦០ថ្ងៃ
-ការប្រព្រឹត្តិអំពើគំរោះគំរើយដល់នៅអ្នកក្រោមបង្គាប់ ឬជនណាមួយនៅក្រោមឱវាទរបស់ខ្លួន			៤០ថ្ងៃ
-ការធ្វើបាបទៅលើអ្នកក្រោមបង្គាប់ឬក្រោមឱវាទ			៣០ថ្ងៃ
-ការរំលោភសិទ្ធិរបស់អ្នកនៅក្រោមបង្គាប់			៣០ថ្ងៃ
ការប្រមាថ និងបំពានលើរូបរាងកាយ			
-ការប្រមាថមើលងាយដល់ទង់ជាតិ ឬកងទ័ព			៦០ថ្ងៃ
-ការភ្លេចគោរពទង់ជាតិ			២០ថ្ងៃ

-ការរំលោភ ការកំហែង ការប្រទេចប្រទាង ការឆ្លើយត្រគោះបោះបោក ដល់អ្នកមានបណ្តាស័ក្តិធំជាង			៦០ថ្ងៃ
-ការបណ្តោយអោយនរណាម្នាក់ធ្វើទុកបុកម្នេញ			៦០ថ្ងៃ
-ការខ្វះខាតក្នុងការគោរព និងអាកប្បកិរិយាប្រទេចប្រទាងដល់អ្នកមានបណ្តាស័ក្តិធំជាង			៣០ថ្ងៃ
-ការគំរាមកំហែង ដើម្បីនឹងដាក់ពាក្យតវ៉ា			២០ថ្ងៃ
-ការគំរោះគំរើយដល់អ្នកយាម ឬភ្នាក់ងារមានសមត្ថកិច្ច			៦០ថ្ងៃ

នាយទាហាន

ប្រភេទទី ៤

ការខ្វះខាតក្នុងការអនុវត្តន៍ជាផ្លូវការ

ហេតុផល	ទោសកំហុសដែលត្រូវដាក់		
	ការព្រមាន	ការស្តីបន្ទោស	ការស្តីបន្ទោសដោយលាយល័ក្ខណអក្សរ ឬការផ្អាកមុខដំណែង

-ការខ្វះខាតយ៉ាងធ្ងន់ធ្ងរ ចំពោះក្បួនច្បាប់ នៃការងារ			៦០ថ្ងៃ
បទល្មើសចំពោះសេចក្តីបង្គាប់អាជ្ញា			
-ការប្រព្រឹត្តិបទល្មើស ដោយគិតទុកជាមុន (ដោយចេតនា) ក្នុងវិន័យយោធា ឬក្នុងសេចក្តីបង្គាប់			៣០ថ្ងៃ
-ការមិនស្តាប់បង្គាប់ ការបង្គាប់របស់អ្នកយាម			៤៥ថ្ងៃ
-ការមិនបានប្រព្រឹត្តិ តាមវិន័យយោធា និងសេចក្តីបង្គាប់ការ			៣០ថ្ងៃ
-ការប៉ុនប៉ងប្រព្រឹត្តបទល្មើស ចំពោះវិន័យយោធា ឬសេចក្តីបង្គាប់ការ	X		
-ការធ្វើវិនិយោគក្នុងមុខងារ ឬ ការទទួលខុសត្រូវ ឬការបណ្តោយអោយមាន ការប្រព្រឹត្តិបទល្មើស ចំពោះវិន័យកងទ័ព រាល់បទបញ្ជា ឬរាល់សេចក្តីបង្គាប់			៤៥ថ្ងៃ
-ការមិនប្រព្រឹត្តិតាមកិច្ចសន្យា បញ្ញត្តិ សេចក្តីបង្គាប់ការនិងវិន័យយ៉ាងល្អិតល្អន់ (វិន័យពិសេសនៅក្នុងធរមានបញ្ញត្តិ ក្នុងកងឯកភាព ឬក្នុងជួរកងទ័ព)	X		
-ការធ្វេសប្រហែស ក្នុងការប្រព្រឹត្តិតាមសេចក្តីបង្គាប់ ឬបញ្ញត្តិណាមួយ	X		
ការបោះបង់មូលដ្ឋាន			
-ការចាកចេញពីមូលដ្ឋាន ដោយគ្មានសេចក្តីអនុញ្ញាត			៦០ថ្ងៃ
-ការមិនទៅដល់មូលដ្ឋាន ដែលបានកំណត់អោយទៅបំរើការងារ			៦០ថ្ងៃ
-ការអវត្តមានតែមួយស្របក់ នៅក្នុងកន្លែង			៤៥ថ្ងៃ

បំពេញការងារ			
-ការអវត្តមានតែមួយស្របក់ ដោយមិនចេញឆ្ងាយពីមូលដ្ឋាន	X		
-ការបោះបង់ចោលកន្លែងហ្វឹកហាត់ ឬកិច្ចការផ្សេងៗ ដែលបានកំណត់អោយ			៣០ថ្ងៃ
-ការដែលនៅក្នុងករណីជំនួសមុខការ ដោយគ្មានការអនុញ្ញាត			១៥ថ្ងៃ
-ការដែលនាយរថយន្ត ឬអ្នកបើកបរ បានចាកចេញពីរថយន្តដោយឥតច្បាប់ ឬផ្ញើទុកនឹងគេដោយគ្មានច្បាប់អនុញ្ញាតនូវរថយន្ត ឬទុកក្ដាររបស់ខ្លួនកាន់កាប់			២០ថ្ងៃ
-ការចាកចេញពីរថយន្តរយៈពេលខ្លី (មួយស្របក់) ដោយគ្មានច្បាប់អនុញ្ញាត	X		
ការខ្វះខាតនៅក្នុងកិច្ចការយាមកាម ក្នុងពេលយប់ និងប្រចាំការ			
-ការធ្វេសប្រហែសក្នុងកិច្ចការយាមកាមកិច្ចការត្រួតពិនិត្យ			៦០ថ្ងៃ
-ការដេកក្នុងពេលយាមកាម និងការត្រួតពិនិត្យ			៣០ថ្ងៃ
-កំហុសយ៉ាងធ្ងន់ទៅលើការត្រួតពិនិត្យ ពួកប្រចាំការ-នាយប្រចាំសប្ដាហ៍ នាយយាមកាម នាយត្រួតពិនិត្យ១៥នាទីម្ដង និងយាមល្បាតក្រុមទាហាន ដែលរៀបចំជាស្រេចនៅពេលចេញប្រតិបត្តិការ			៣០ថ្ងៃ
-ការមិនដើរល្បាតតាមស្ថានភាព ដែលកំណត់អោយ			២០ថ្ងៃ
-ការដើរចោលទីកន្លែង ក្នុងអំឡុងពេលយាមកាម១៥នាទីម្ដងដោយគ្មានអ្នកជំនួស			១០ថ្ងៃ

-ការមិនងើបពីដេកដល់ពេលវេលា ដែលត្រូវយាមកាម			១៥ថ្ងៃ
-ការមកដោយយឺតយ៉ាវក្នុងពេលយាមកាម			១០ថ្ងៃ
ការប្រព្រឹត្តបទល្មើស មកមិនទាន់ពេលវេលា នៅពេលបំពេញមុខងារ			
-ការមកមិនទាន់ពេលធ្វើការ ឬចេញពីធ្វើការមុនម៉ោង			១០ថ្ងៃ
-ការអនុវត្តន៏ការងារមិនល្អដោយចេតនា			៦០ថ្ងៃ
-ការមានបំណងមិនល្អ ជានិច្ចកាលនៅក្នុងមុខងារ			៣០ថ្ងៃ
-ការមិនបានព្យាបាលខ្លួន នៅពេលមានជម្ងឺដើម្បីគេចវេះពីការងារ			២០ថ្ងៃ
-ការដែលបង្ហាញខ្លួន នៅពេលទៅមន្ទីរពេទ្យដោយសាមីខ្លួនមានជម្ងឺដើម្បីគេចវេះពីការងារ			៣០ថ្ងៃ
-ការមិនបានទៅ នៅពេលចេញទៅហ្វឹកហ្វឺន			១៥ថ្ងៃ
-ការមិនបានទៅបង្ហាញខ្លួន នៅពេលត្រួតពិនិត្យ	X		
ការប្រព្រឹត្តិនូវក្បួនខ្នាត សន្តិសុខ និង សេចក្តីបង្គាប់ជាដាច់ខាត នៃអនាម័យ			
-ការខ្វះខាត និងអនុវត្តក្បួនខ្នាតសន្តិសុខ			៤៥ថ្ងៃ
-ការខ្វះខាត និងអនុវត្តក្បួនខ្នាតអនាម័យ			២០ថ្ងៃ
-ការដក់បារី ធ្វើអោយភ្លើងឆេះនៅជិតឃ្លាំងគ្រាប់ ឃ្លាំងសាំង និងឃ្លាំងដែលមានគ្រឿងផ្ទុះ			៣០ថ្ងៃ
-ការលេងអាវុធ លេងគ្រាប់ដោយគ្មានច្បាប់			២០ថ្ងៃ
-ការមិនអនុវត្តន៏តាមសេចក្តីបង្គាប់របស់ពេទ្យ	X		
-ការចោលកំទេច ឬកាកអ្វីក្រៅពីកន្លែងបានកំហិតអោយ	X		

-ការនាំចូលនូវអាវុធផ្ទាល់ខ្លួន ក្នុងបរិវេណយោធាដោយគ្មានការអនុញ្ញាត			៣០ថ្ងៃ
-ការកាន់អាវុធ គ្រាប់បែក គ្រឿងផ្ទុះដោយខុសច្បាប់			២០ថ្ងៃ
-ការកែប្រែសំភារៈសព្វាវុធ គ្រាប់រំសេវទាំងឡាយដោយគ្មានច្បាប់			៣០ថ្ងៃ
-ការឃោគយល់ជួយណែនាំអោយប្រព្រឹត្ត នូវគ្រឿងញៀន			៦០ថ្ងៃ
-ការប្រើប្រាស់គ្រឿងញៀន			៣០ថ្ងៃ
-ការនាំចូលដោយគ្មានច្បាប់អនុញ្ញាត ក្នុងបរិវេណយោធា មានគ្រឿងញៀន មានជាតិស្រាហើយនិងគ្រឿងផ្ទុះ			៣០ថ្ងៃ
-ការញុះញង់អោយប្រើគ្រឿងស្រវឹងដោយហួសហេតុ			៤៥ថ្ងៃ
-ការប្រព្រឹត្តមិនស្អាតស្អំ			២០ថ្ងៃ
-ការចេញចូលក្នុងកន្លែងហាមឃាត់			០៨ថ្ងៃ
-បទល្មើសនឹងច្បាប់ក្នុងការជក់បារី			១៥ថ្ងៃ
-ការហាលខោអាវមិនតាមច្បាប់ទម្លាប់	X		
-ការដេកខុសកន្លែង ដែលបានកំណត់អោយ	X		
-ការងូតទឹកមិនត្រឹមត្រូវ	X		
-ការមិនថែទាំសំភារៈ និងលុយកាក់ផ្ទាល់ខ្លួន	X		
ការហាមឃាត់ផ្សេងៗ			
-ការមិនអនុវត្តន៏តាមក្បួនច្បាប់ នៅពេលដែលយើងទៅសំរាកនៅប្រទេសក្រៅ			១០ថ្ងៃ
-ការនាំមនុស្សក្រៅចូលមកក្នុងបរិវេណយោធា			២០ថ្ងៃ
ការប្រើប្រាស់ ដោយគ្មានសណ្តាប់ធ្នាប់ យានជំនិះ ឬសំភារៈយោធា			
-ការប្រើប្រាស់ដោយគ្មានច្បាប់ ហើយគ្មាន			៦០ថ្ងៃ

សណ្តាប់ធ្នាប់នូវយានជំនិះ និងសំភារៈយោធា			
-ការបង្វែងដានដោយចេតនា នូវគោលដៅដែលត្រូវទៅ			១០ថ្ងៃ
-ការដឹកនាំជនស៊ីវិលតាមរថយន្តយោធា ដោយគ្មានច្បាប់អនុញ្ញាត			២០ថ្ងៃ
-ការដឹកនាំយោធា និងសំភារៈផ្សេងៗ ដោយគ្មានច្បាប់អនុញ្ញាត			៣០ថ្ងៃ
-ការប្រើប្រាស់ដោយគ្មានច្បាប់ នូវសំភារៈរាជការសំរាប់ប្រយោជន៏ផ្ទាល់ខ្លួន			៤៥ថ្ងៃ
បទល្មើសនឹងច្បាប់ ក្នុងកិច្ចការពារការសម្ងាត់			
-ការមិនចេះលាក់នូវអាថ៌កំបាំង ដោយរំាហារឬសរសេរដែលបណ្តាលអោយមានវិបត្តិយ៉ាងធ្ងន់			៦០ថ្ងៃ
-ការទាក់ទងជាមួយមនុស្សដែលគ្មានសមត្ថភាពដែលដឹងការសម្ងាត់			៦០ថ្ងៃ
-ការធ្វើអោយបាត់បង់ឯកសារ			៦០ថ្ងៃ
-ការកាន់កាប់ឯកសារដោយគ្មានច្បាប់អនុញ្ញាត			៣០ថ្ងៃ
-ការធ្វេសប្រហែសក្នុងការរាយការណ៏ ពីការបាត់បង់ខូចខាតសំភារៈ គ្រោះថ្នាក់ក្នុងពេលដែលយើងគ្រប់គ្រង			៣០ថ្ងៃ

នាយទាហាន

ប្រភេទទី ៥

កំហុសនឹងការធ្វេសប្រហែសនៅក្នុងមុខងារ

ហេតុផល	កំហុសដែលត្រូវដាក់		
	ការព្រមាន	ការស្តីបន្ទោស	ការស្តីបន្ទោសដោយលាយល័ក្ខណអក្សរ ឬការផ្អាកមុខដំណែង
-ការមានកំហុសជាទម្ងន់ដោយធ្វេសប្រហែស នៅក្នុងមុខងារដែលបណ្តាលអោយមានគ្រោះថ្នាក់ដល់អាយុជីវិត ឬខូចខាតយ៉ាងធ្ងន់ធ្ងរដល់សំភារៈ			៦០ថ្ងៃ
-ការបាត់បង់សំភារៈ ឬឯកសារផ្សេងៗ			៣០ថ្ងៃ
-ការមិនរាយការណ៍នៅពេលបាត់អត្តសញ្ញាណប័ណ្ណ			២០ថ្ងៃ

នាយទាហាន

ប្រភេទទី ៦

កំហុសប៉ះពាល់ដល់កិរិយាមារយាទល្អ

(កំហុសអាកប្បកិរិយា និងឯកសណ្ឋាន)

ហេតុផល	ទោសកំហុសដែលត្រូវដាក់		
	ការព្រមាន	ការស្តីបន្ទោស	ការស្តីបន្ទោសដោយលាយល័ក្ខណអក្សរ ឬការផ្អាកមុខដំណែង
-ការប៉ះពាល់យ៉ាងធ្ងន់ដល់កិរិយាមារយាទ បទល្មើសក្នុងការស្លៀកពាក់ឯកសណ្ឋាន			៦០ថ្ងៃ
-ការស្លៀកពាក់ឯកសណ្ឋានផ្ទុយនឹងអនុក្រឹត្យ នៅក្នុងបរិវេណអង្គភាពទ័ព			៣០ថ្ងៃ

-ការស្លៀកពាក់ឯកសណ្ឋាន ផ្ទុយនឹងបទបញ្ជាផ្ទៃក្នុង នៅក្នុង ឬក្បែរបរិវេណកងទ័ព			១៥ថ្ងៃ
-ការស្លៀកពាក់ឯកសណ្ឋានផ្ដេសផ្ដាស់ គគ្រិចនៅក្រៅបរិវេណអង្គភាព			២០ថ្ងៃ
-ការស្លៀកពាក់ឯកសណ្ឋានផ្ដេសផ្ដាស់ គគ្រិចនៅក្នុង ឬក្បែរបរិវេណអង្គភាព			០៤ថ្ងៃ
-ការដែលមិនស្លៀកពាក់សមស្របតាមបទបញ្ញត្តិ	X		
-ការប្រើប្រាស់ឯកសណ្ឋានស៊ីវិល ហ៊ឺហារហួសហេតុក្នុងបរិវេណយោធា	X		
កំហុសក្នុងការប្រព្រឹត្តិ			
-ការប្រព្រឹត្តិនូវបាបកម្ម			៦០ថ្ងៃ
-ការបង្កហេតុធ្វើឱ្យបាត់សណ្ដាប់ធ្នាប់ ក្នុងពេលបំពេញការងារ ឬចេញប្រតិបត្តិការ			៤៥ថ្ងៃ
-ការបង្កហេតុ ឬប្រព្រឹត្តិបាបកម្មនៅក្រៅបរិវេណកងឯកភាព			៣០ថ្ងៃ
-ការបង្កហេតុ ឬប្រព្រឹត្តិបាបកម្មនៅក្នុងបរិវេណកងឯកភាព			៣០ថ្ងៃ
-ការស្រវឹងស្រាដែលនាំអោយរាំងស្ទះក្នុងកិច្ចការ			៣០ថ្ងៃ
-ការស្រវឹងស្រា នៅពេលបំពេញកិច្ចការ			៤៥ថ្ងៃ
-ការស្រវឹងស្រា ប្រព្រឹត្តិបាបកម្មនៅក្រៅបរិវេណកងឯកភាព			៤៥ថ្ងៃ
-ការធ្វើទុក្ខបុកម្នេញ ចំពោះមិត្តភ័ក្តិ			៦០ថ្ងៃ
-ការធ្វើទុក្ខបុកម្នេញធម្មតា			៤៥ថ្ងៃ
-ការមិនបានធ្វើអន្តរាគមន៍ នៅពេលឃើញគេធ្វើទុក្ខបុកម្នេញអ្នកដទៃ			៦០ថ្ងៃ
-ការប្រព្រឹត្តិអំពើឃោរឃៅ ធ្វើអោយបាក់មុខមាត់ ដោយអាម៉ាស់ទៅលើមិត្តភ័ក្តិ			៣០ថ្ងៃ

-ការរួមគំនិត ធ្វើអោយអាម៉ាស់ ឬបាក់មុខមាត់ -ការជាល់តប់ ឬឈ្លោះប្រកែកគ្នា -ការផលិត ឬកែច្នៃសំរាប់អាជីវកម្ម ទិញលក់អាវុធគ្រាប់រំសេវ ជាតិផ្ទុះផ្សេងៗ			៣០ថ្ងៃ ១៥ថ្ងៃ ៦០ថ្ងៃ

<u>ឧបសម្ព័ន្ធទី២.-</u>

តារាងកំរិតសិទ្ធិ នៃការស្នើសុំដាក់ទណ្ឌកម្ម

ដល់ពលទាហាន(១)

មុខងារ ឬឋានៈ ប្រហាក់ប្រហែល	*ការព្រមាន*	*ការជាប់បញ្ញត្តិ*	*ការផ្អាកមុខដំណែង*	*សេចក្តីផ្សេងៗ*
មេក្រុម		១ថ្ងៃ		
កងអនុសេនាតូច-ប្រហាក់ប្រហែល	X	២ថ្ងៃ	២ថ្ងៃ	
កងអនុសេនាធំ-ប្រហាក់ប្រហែល	X	៤ថ្ងៃ	៤ថ្ងៃ	
កងវរសេនាតូច-ប្រហាក់ ប្រហែល	X	៨ថ្ងៃ	៨ថ្ងៃ	
កងវរសេនាធំ-ប្រហាក់ ប្រហែល	X	១៥ថ្ងៃ	១៥ថ្ងៃ	
កងពលតូច-ថ្នាក់ប្រហាក់ ប្រហែល	X	២០ថ្ងៃ	២០ថ្ងៃ	បន្ថយថ្នាក់ពលឯក មក ពលទោ
យោធភូមិភាគ-កងពលធំ			៣០ថ្ងៃ	បន្ថយឋានន្តរស័ក្តិមួយថ្នាក់
ប្រភេទទ័ព-កងរាជអាវុធហត្ថ			៣០ថ្ងៃ	បន្ថយឋានន្តរស័ក្តិមួយថ្នាក់
អគ្គមេបញ្ជាការ			៤៥ថ្ងៃ	បន្ថយឋានន្តរស័ក្តិមួយថ្នាក់
ក្រសួងការពារជាតិ			៦០ថ្ងៃ	បន្ថយឋានន្តរស័ក្តិមួយថ្នាក់

តារាងកំរិតសិទ្ធិ នៃការស្នើសុំដាក់ទណ្ឌកម្ម ដល់នាយទាហានរង(២)

មុខងារ ឬឋានៈ ប្រហាក់ប្រហែល	*ការព្រមាន*	*ការស្តីបន្ទោស*	*ការស្តីបន្ទោសដោយលាយលក្ខណ៍អក្សរ ឬ ការផ្អាកមុខដំណែង*
កងអនុសេនាតូច-ប្រហាក់ប្រហែល	X		២ថ្ងៃ
កងអនុសេនាធំ-ប្រហាក់ប្រហែល	X	X	៤ថ្ងៃ
កងវរសេនាតូច-ប្រហាក់ប្រហែល	X	X	៦ថ្ងៃ
កងវរសេនាធំ-ប្រហាក់ប្រហែល	X	X	១០ថ្ងៃ
កងពលតូច-ថ្នាក់ប្រហាក់ប្រហែល			១៥ថ្ងៃ
យោធភូមិភាគ-កងពលធំ			៣០ថ្ងៃ
ប្រភេទទ័ព-កងរាជអាវុធហត្ថ			៣០ថ្ងៃ
អគ្គមេបញ្ជាការ			៤៥ថ្ងៃ
ក្រសួងការពារជាតិ			៦០ថ្ងៃ

តារាងកំរិតសិទ្ធិ នៃការស្នើសុំដាក់ទណ្ឌកម្ម ដល់នាយទាហាន(៣)

មុខងារ ឬឋានៈ ប្រហាក់ប្រហែល	*ការព្រមាន*	*ការស្តីបន្ទោស*	*ការស្តីបន្ទោសដោយលាយលក្ខណ៍អក្សរ ឬ ការផ្អាកមុខដំណែង*
កងអនុសេនាធំ-ប្រហាក់ ប្រហែល	X		២ថ្ងៃ
កងវរសេនាតូច-ប្រហាក់ ប្រហែល	X		៦ថ្ងៃ
កងវរសេនាធំ-ប្រហាក់ ប្រហែល	X	X	១០ថ្ងៃ
កងពលតូច-ថ្នាក់ប្រហាក់ ប្រហែល			១៥ថ្ងៃ
យោធភូមិភាគ-កងពលធំ			៣០ថ្ងៃ

ប្រភេទទ័ព-កងរាជអាវុធហត្ថ			៣០ថ្ងៃ
អគ្គមេបញ្ជាការ			៤៥ថ្ងៃ
ក្រសួងការពារជាតិ			៦០ថ្ងៃ

កំណត់ចំណាំ : (១)-(២) និង (៣)

នាយទាហាន និងនាយទាហានរងអាចមានសិទ្ធិស្នើសុំដាក់ទណ្ឌកម្មដល់យោធិន ដែលពុំដែលនៅក្នុងកងឯកភាព (បំរើការកងឯកភាពផ្សេង) របស់ខ្លួន បានពាក់កណ្តាលតាមកំរិត ដែលបានចែងខាងលើនេះ។

កាលណានាយទាហានណាម្នាក់ បានប្រព្រឹត្តខុសច្បាប់ យោធិននោះត្រូវទទួលទណ្ឌកម្ម អ្នកសុំអោយដាក់ទណ្ឌកម្មក្រៅពីកងឯកភាព ឬក្នុងកងឯកភាពក៏ដោយ ត្រូវធ្វើលិខិតស្នាម នៃការដាក់ទណ្ឌកម្ម ផ្ញើមកមេបញ្ជាការកងឯកភាព ដោយមានចែងជាយថាហេតុផង ។

មេបញ្ជាការ ឬមេបញ្ជាការរងត្រូវហៅនាយទាហាននោះមកសាកសួរ ហើយដាក់ទណ្ឌកម្ម តាមកំរិតដែលបានចែងមកស្រាប់ រួចត្រូវផ្ញើបន្តទៅមេបញ្ជាការយោធភូមិភាគ ប្រភេទទ័ព កងរាជអាវុធហត្ថ អគ្គមេបញ្ជាការ និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ហើយត្រូវប្រាប់ទៅអ្នកដែលបានសុំធ្វើទោសនោះផង។ បើទោសណាដែលត្រូវផ្ញើទៅតុលាការសឹកនោះ ត្រូវផ្ញើមករដ្ឋមន្ត្រី ក្រសួងការពារជាតិជាច់ខាត។

កំណត់ចំណាំ : មេបញ្ជាការផ្ទាល់អាចដាក់ទោសដល់យោធិនភ្លាម១បាន នៅពេលដែលយោធិននោះប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរជាក់ស្តែង រួចហើយមេបញ្ជាការនោះត្រូវធ្វើសំណុំបែបបទស្តីពីការដាក់ទោស ផ្ញើជូនទៅមេបញ្ជាការថ្នាក់លើបន្តបន្ទាប់។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤០ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន នៃក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើររបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

ត្រូវបានបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន ស្ថិតនៅចំណុះនាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

ការបង្កើតនាយកដ្ឋាននេះ ក្នុងទិសដៅផ្តល់សេវាឯកទេសក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់សកម្មភាពជួញដូរមនុស្ស អាជីវកម្មផ្លូវភេទលើនីតិជននិងអនីតិជនតាមនីតិវិធីច្បាប់ នៃ ព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញាអន្តរជាតិនានា។

ជំពូកទី២
អំពីរចនាសម្ព័ន្ធគ្រប់គ្រង

មាត្រា២.-

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

មាត្រា៣.-

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន មានការិយាល័យមួយចំនួនចំណុះ ។

ការរៀបចំរចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងមន្ត្រីរបស់ការិយាល័យចំណុះនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ជំពូកទី៣
អំពីសមត្ថកិច្ច និងភារកិច្ច

មាត្រា៤.-

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនមានសមត្ថកិច្ច និងភារកិច្ច ដូចខាងក្រោម :

- ផ្ដើមយោបល់លើកឡើងនូវគោលការណ៍ ជូនថ្នាក់ដឹកនាំក្រសួង អគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីដាក់ចេញនូវផែនការ វិធានការប្រឆាំងការជួញដូរមនុស្ស អាជីវកម្មផ្លូវភេទលើនីតិជន អនីតិជន និងកាមសាស្ត្រលើកុមារ (អំពើអនាចារលើកុមារ) ។
- ចាប់ខ្លួនចារី សហចារី ដកហូតសំភារៈ វត្ថុតាងពាក់ព័ន្ធកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។
- អនុវត្តតាមសាលក្រម សាលដីការបស់តុលាការពាក់ព័ន្ធករណីជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ លើនីតិជន និងអនីតិជន ។
- សហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ដើម្បីកសាងផែនការយុទ្ធសាស្ត្រ និងសកម្មភាពក្នុងការប្រឆាំងការជួញដូរមនុស្ស អាជីវកម្មផ្លូវភេទលើនីតិជន និងអនីតិជន ។
- សហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ដើម្បីស្វែងរកការផ្ដល់ជំនួយឯកទេស ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស អាជីវកម្មផ្លូវភេទលើនីតិជន អនីតិជនក្នុងប្រទេស និងសកម្មភាពឆ្លងដែន ។
- សិក្សាស្រាវជ្រាវស្ដីពីការលំបាក និងងាយស្រួលក្នុងនីតិវិធីប្រតិបត្តិរបស់នគរបាលចំណុះនាយកដ្ឋាន និងតាមស្នងការដ្ឋាននគរបាលខេត្ត-ក្រុង ។

- សម្របសម្រួលលើការអនុវត្តច្បាប់ ដោយទំនាក់ទំនងជាមួយព្រះរាជអាជ្ញាតុលាការ ដែលពាក់ព័ន្ធដល់ការងារ និងសកម្មភាពប្រតិបត្តិការរបស់នាយកដ្ឋាន ។
- គ្រប់គ្រង និងផ្តល់ពត៌មាន ពីមុខសញ្ញាក្នុងប្រទេស និងមុខសញ្ញាឧក្រិដ្ឋអន្តរជាតិ ដែលពាក់ព័ន្ធសកម្មភាពការជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ លើនីតិជន និងអនីតិជន ។
- ធ្វើរបាយការណ៍ជាប្រចាំ តាមការកំណត់ឬជាបន្ទាន់អំពីសភាពការណ៍ ហេតុការណ៍ផ្សេងៗដែលពាក់ព័ន្ធដល់ការអនុវត្តភារកិច្ចរបស់ខ្លួនជូនដល់អគ្គស្នងការនគរបាលជាតិ ។
- ប្រតិបត្តិយ៉ាងម៉ឹងម៉ាត់ និងខ្ជាប់ខ្ជួននូវវិន័យរបស់នគរបាលជាតិ កសាងស្មារតី និងកិត្តិយសរបស់នគរបាលជាតិ ។
- ធ្វើការងារបុគ្គលិក រដ្ឋបាល ភស្តុភារ គណនេយ្យរបស់នាយកដ្ឋានតាមការកំណត់របស់ក្រសួង ។
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ប្រគល់អោយ ។

ជំពូកទី៤

អវសានប្បញ្ញត្តិ

មាត្រា៥.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសាផ្ទុយនិងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤១ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការរៀបចំកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើររបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

ត្រូវបានរៀបចំកែសំរួលនាយកដ្ឋាននគរបាលរដ្ឋបាល និងនាយកដ្ឋានសន្តិសុខសង្គមទៅជានាយកដ្ឋាននគរបាលស្ថិតិ និងលិខិតឆ្លងដែន និងនាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គីភ័យ ដែលស្ថិតនៅចំណុះនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ។

ការរៀបចំកែសំរួលនាយកដ្ឋានទាំងពីរនេះ ក្នុងទិសដៅពង្រឹងតួនាទី ភារកិច្ច និងបង្កើនសមត្ថភាពលើការងារដឹកនាំគ្រប់គ្រងកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ ការចុះបញ្ជីស្ថិតិប្រជាពលរដ្ឋ ការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ការផ្តល់លិខិតឆ្លងដែនជូនប្រជាពលរដ្ឋ ការ

ចុះបញ្ជីមុខរបបពិសេស គ្រប់គ្រងអាវុធ ជាតិផ្ទុះ និងការងារបង្ការ ពន្លត់អគ្គិភ័យអោយកាន់តែមានប្រសិទ្ធភាពថែមទៀត ។

ជំពូកទី២
អំពីរចនាសម្ព័ន្ធគ្រប់គ្រង

មាត្រា២.-

- នាយកដ្ឋាននគរបាលស្ថិតិ និងលិខិតឆ្លងដែនដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

- នាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គិភ័យ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

មាត្រា៣.-

នាយកដ្ឋាននគរបាលស្ថិតិនិងលិខិតឆ្លងដែន និងនាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គិភ័យ មាន ការិយាល័យមួយចំនួន ចំណុះ ។

ការរៀបចំរចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងបរិមាណមន្ត្រីរបស់ការិយាល័យចំណុះ នៃនាយកដ្ឋានទាំងពីរខាងលើកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ជំពូកទី៣
អំពីសមត្ថកិច្ច និងភារកិច្ច

មាត្រា៤.-

នាយកដ្ឋាននគរបាលស្ថិតិ និងលិខិតឆ្លងដែន មានសមត្ថកិច្ច និងភារកិច្ចដូចខាងក្រោម :

១- ពិចារណាផ្តើមយោបល់អំពីគោលការណ៍ ជូនថ្នាក់ដឹកនាំក្រសួង អគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីដាក់ចេញនូវផែនការ វិធានការជាក់ស្តែងសំដៅលើកកំពស់ប្រសិទ្ធភាពការងារ :

- គ្រប់គ្រងការចុះបញ្ជីស្ថិតិប្រជាពលរដ្ឋ
- គ្រប់គ្រងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋ
- ពិនិត្យផ្តល់ និងគ្រប់គ្រងលិខិតឆ្លងដែនជូនប្រជាពលរដ្ឋ
- គ្រប់គ្រងការចុះបញ្ជីមុខរបរពិសេស

២- សហការស្រាវជ្រាវរកមនុស្សបាត់ខ្លួន និងគ្រួសារដែលបាត់ដំណឹង ។

៣- ផ្តើមគោលការណ៍ជូនថ្នាក់ដឹកនាំក្រសួង អគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីដាក់ចេញនូវវិធានការ បង្ការទប់ស្កាត់និងបង្ក្រាបអំពើល្មើសច្បាប់ដែលពាក់ព័ន្ធដល់ការងារស្ថិតិ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ការផ្តល់លិខិតឆ្លងដែនជូនប្រជាពលរដ្ឋ និងមុខរបរពិសេស ។

៤- សិក្សាស្រាវជ្រាវអំពីស្ថានភាព ភូមិសាស្ត្រ ស្ថានភាពប្រជាពលរដ្ឋ ដើម្បីពិចារណាដាក់ចេញនូវផែនការអំពីការកំណត់ទីតាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់និងការបំពាក់សំភារៈ

ឧបករណ៍មធ្យោបាយផ្សេងៗ អោយបានសមស្របទៅតាមសភាពការជាក់ស្តែងតាមតំបន់ភូមិសាស្ត្រ និងតាមដំណាក់កាលនីមួយៗ ដើម្បីធានាកិច្ចប្រតិបត្តិការឱ្យមានប្រសិទ្ធភាពខ្ពស់ ។

៥- តាមដានជាប្រចាំអំពីសភាពការណ៍និងការវិវត្តន៍ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់នៅទូទាំងប្រទេស តាមដំណាក់កាលនីមួយៗ ដើម្បីរាយការណ៍ និងលើកសំណូមពរជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីមានគោលការណ៍ វិធានការចំពោះមុខ និង យូរអង្វែង លើកិច្ចការអភិវឌ្ឍន៍ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ឱ្យរៀបរយជាបណ្តើរៗ សមស្របតាមសភាពការណ៍រីកចំរើនក្នុងតំបន់ និងសកលលោក ។

៦- ធ្វើរបាយការណ៍ជាប្រចាំ តាមការកំណត់ឬជាបន្ទាន់អំពីសភាពការណ៍ ហេតុការណ៍ផ្សេងៗ ដែលពាក់ព័ន្ធដល់ការអនុវត្តភារកិច្ចរបស់ខ្លួនជូនដល់អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ។

៧- ប្រតិបត្តិយ៉ាងម៉ឺងម៉ាត់ និងខ្ជាប់ខ្ជួននូវវិន័យរបស់នគរបាលជាតិ កសាងស្នាដៃនិងកិត្តិយសរបស់នគរបាលជាតិ ។

៨- ធ្វើការងារបុគ្គលិក រដ្ឋបាល ភស្តុភារ គណនេយ្យរបស់នាយកដ្ឋានតាមការកំណត់របស់ក្រសួង ។

៩- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ប្រគល់អោយ ។

មាត្រា៥.-

នាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ និងអគ្គិភ័យមានសមត្ថកិច្ច និងភារកិច្ចដូចខាងក្រោម :

១- ផ្តើមយោបល់ លើកឡើងនូវគោលការណ៍ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីដាក់ចេញនូវផែនការ វិធានការណ៍សំដៅលើកកំពស់ប្រសិទ្ធភាពការងារគ្រប់គ្រងអាវុធជាតិផ្ទុះ និងការងារបង្ការ និងពន្លត់អគ្គិភ័យ ។

២- គ្រប់គ្រងការចុះបញ្ជី និងរៀបចំបែបបទផ្តល់លិខិតអនុញ្ញាតិប្រើប្រាស់អាវុធ តាមការកំណត់របស់រាជរដ្ឋាភិបាល ។

៣- ចុះតាមដានត្រួតពិនិត្យ និងណែនាំអំពីជំនាញគ្រប់គ្រងអាវុធ ជាតិផ្ទុះ នៅតាមស្នងការដ្ឋាននគរបាលខេត្ត-ក្រុង ។

៤- ណែនាំ និងជំរុញដល់ការងារស្រាវជ្រាវ ដើម្បីរកឱ្យឃើញអាវុធជាតិផ្ទុះគ្រប់ប្រភេទដែលប្រើប្រាស់ ដឹកជញ្ជូន និងផ្ទេរ ទិញលក់ខុសច្បាប់ ។

៥- គ្រប់គ្រងការចុះបញ្ជីមូលដ្ឋានធ្វើអាជីវកម្ម និងមូលដ្ឋានផលិតកម្ម ដែលប្រើប្រាស់ជាតិផ្ទុះ ។

៦- គ្រប់គ្រង ដឹកនាំបញ្ជា ការងារបង្ការពន្លត់អគ្គិភ័យ និងសហការជាមួយកំលាំងសមត្ថកិច្ចផ្សេងៗទៀត ក្នុងការអង្កេត ស្រាវជ្រាវ និងធ្វើកោសល្យវិនិច្ឆ័យ នៃអគ្គិភ័យ ។

៧- ចុះហ្វឹកហ្វឺនដល់កំលាំងជំនាញឯកទេស ពន្លត់អគ្គិភ័យនៅតាមក្រសួងស្ថាប័ន គ្រឹះស្ថានសិក្សា រោងចក្រ សហគ្រាស និងកំលាំងពន្លត់អគ្គិភ័យរបស់ស្នងការដ្ឋាននគរបាលខេត្ត-ក្រុង ។

៨- ឃោសនា ផ្សព្វផ្សាយអំពីវិធានការបង្ការទប់ស្កាត់ នៃគ្រោះមហន្តរាយ ដែលកើតឡើងដោយអគ្គីភ័យ ។

៩- គ្រប់គ្រងថែរក្សារថយន្ត និងឧបករណ៍ សំភារៈ សំរាប់បំរើឱ្យការងារពន្លត់អគ្គីភ័យ ។

១០- ធ្វើរបាយការណ៍ជាប្រចាំ តាមការកំណត់ឬជាបន្ទាន់អំពីសភាពការណ៍ ហេតុការណ៍ផ្សេងៗ ដែលពាក់ព័ន្ធដល់ការអនុវត្តភារកិច្ចរបស់ខ្លួនជូនដល់អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ។

១១- ប្រតិបត្តិយ៉ាងម៉ឺងម៉ាត់ និងខ្ជាប់ខ្ជួននូវវិន័យរបស់នគរបាលជាតិ កសាងស្នាដៃ និង កិត្តិយសរបស់នគរបាលជាតិ ។

១២- ធ្វើការងារបុគ្គលិក រដ្ឋបាល ភស្តុភារ គណនេយ្យរបស់នាយកដ្ឋានតាមការកំណត់របស់ក្រសួង ។

១៣- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃប្រគល់អោយ ។

ជំពូកទី៤

អវសានប្បញ្ញត្តិ

មាត្រា៦.-

នាយកដ្ឋាននគរបាលរដ្ឋបាល និងនាយកដ្ឋានសន្តិសុខសង្គម ត្រូវបានរំសាយចោល ។

មាត្រា៧.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ... ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧២៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ឯកឧត្តម **តាវ សេខហួរ** អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះគ្រូ **ឥន្ទបញ្ញោ ញឹម ម៉ាន់អួន** ព្រះចៅអធិការវត្តគគីរធំ ឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលមានស្នាព្រះហស្តក្នុងការកសាងសមិទ្ធផលផ្សេងៗ ក្នុងវត្តគគីធំដែលចំណាយបច្ច័យសរុបចំនួន **៥៤២,៥៦២,២០០រៀល** ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១និងមាត្រា ២
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២២៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម

ស ំ រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រី នៃក្រសួង ធនធានទឹក និង ឧតុនិយម ចំនួន ០៨ រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមស្តារ ទំនប់ការពារទឹកប្រៃ ព្រៃនប់ ក្នុងខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ដូចមានរាយនាមខាងក្រោមនេះ ÷

ក-មេដាយប្រាក់ការងារ :

-លោក **ពេជ្រ គឹមសាន្ត** ប្រធានមន្ទីរធនធានទឹកនិងឧតុនិយមក្រុងព្រះសីហនុ

ខ-មេដាយសំរឹទ្ធការងារ :

១-លោក	**ឌឹម**	**វុឌ្ឍារី**	មន្ត្រី នាយកដ្ឋានវិស្វកម្ម
២-លោក	**ស្រួយ**	**ស៊្រុន**	មន្ត្រី នាយកដ្ឋានវិស្វកម្ម
៣-លោក	**សុខ**	**ពិសិដ្ឋ**	មន្ត្រី នាយកដ្ឋានវិស្វកម្ម
៤-លោក	**ចាប**	**ឥន្ទ**	មន្ត្រី នាយកដ្ឋានវិស្វកម្ម
៥-លោក	**ផាន់**	**លីតឹក**	មន្ត្រី នាយកដ្ឋានវិស្វកម្ម
៦-លោក	**ជា**	**សុផុន**	មន្ត្រី នាយកដ្ឋានវិស្វកម្ម
៧-លោក	**ម៉ុខ**	**វីរៈ**	មន្ត្រី នាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២២៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសុវត្ថារា

&&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

ស ម្រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **សេនា** ជូនមន្ត្រី តំណាងអង្គការក្រៅរដ្ឋាភិបាល ០២ រូប ដែលមានស្នាដៃល្អ ក្នុងការសហការជួយស្តារទំនប់ការពារទឹកប្រៃ ព្រៃនប់ ក្រុងព្រះសីហនុ ដូចមាននាមខាងក្រោម ÷

១ - លោក **Vincent DAVID** តំណាងអង្គការ **Action Nord Sud**

២ - លោក **Jean François KIBLER** តំណាងអង្គការ **GRET**

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២២៨ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការផ្ទេរភារកិច្ច និងតែងតាំង
នាយនគរបាលជាតិជាន់ខ្ពស់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត / ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការ-តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /ន/ស៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ /១៧៨ ចុះថ្ងៃទី២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

សំរេច

មាត្រា១: ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃដូចមានរាយនាមខាងក្រោម :

១-លោកឧត្តមសេនីយ៍ត្រី ហេង ហាត់ អត្តលេខ ០០៦៣ បច្ចុប្បន្នអនុប្រធានទី១ នាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ ជាអគ្គាធិការរង នៃ អគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និង នគរបាល នៃក្រសួងមហាផ្ទៃ ។

២-លោក ឧត្តមសេនីយ៍ត្រី ឌន អ៊ឹម អត្តលេខ ០០៣២ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ជា អនុប្រធានទី១នាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ នៃ ក្រសួងមហាផ្ទៃ ។

៣-លោកឧត្តមសេនីយ៍ត្រី ពាត គ្រួច អត្តលេខ ០០៣៥បច្ចុប្បន្នប្រធានអធិការដ្ឋានកិច្ចការនគរបាល នៃ អគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាលជាអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន នៃក្រសួងមហាផ្ទៃ ។

៤- លោក ឧត្តមសេនីយ៍ត្រី ថោង លឹម អត្តលេខ ០០៤៨ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន ជាអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នៃក្រសួងមហាផ្ទៃ ។

៥- លោក វរសេនីយ៍ឯក សម សាគុណ អត្តលេខ ០២១៤ បច្ចុប្បន្នអនុប្រធាននាយកដ្ឋាននគរបាលសេដ្ឋកិច្ច ជាប្រធានអធិការដ្ឋានកិច្ចការនគរបាល នៃ អគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល នៃក្រសួងមហាផ្ទៃ ។

៦- លោកវរសេនីយ៍ឯក គ្រី ទូច អត្តលេខ ០១៦៦ បច្ចុប្បន្នអនុប្រធាននាយកដ្ឋាននគរបាលព្រំដែន-គោកជា អនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ នៃក្រសួងមហាផ្ទៃ ។

មាត្រា២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៦២៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **អ៊ុំ សំអាង** ជាជំនួយការផ្ទាល់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ **អនុប្រធាននាយកដ្ឋាន** ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៧៣០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្ត កំពត

ស ំ រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ០៧ រូប ដែលបានបរិច្ចាគថវិកា ជួយកសាងព្រះវិហារ និង សមិទ្ធផលផ្សេងៗ ក្នុងវត្តព្រៃតុម្ព ឃុំព្រៃឃ្មុំ ស្រុកកំពត ខេត្តកំពត ដូចមាននាមខាងក្រោម ÷

១-ព្រះតេជគុណ	**រ័ត្ន**	**ស៊ីវុត្ថា**	គង់នៅរដ្ឋកាលីហ្វ័រញ៉ា (USA)	បច្ច័យ	២៥៥.៨៩៨	USD
២-លោកស្រី	**លី**	**តេចជួន**	នៅរដ្ឋកាលីហ្វ័រញ៉ា (USA)	ថវិកា	៣៥.០០០	USD
៣-លោកស្រី	**កែវ**	**អ៊ា**	នៅរដ្ឋកាលីហ្វ័រញ៉ា (USA)	ថវិកា	២៥.០០០	USD
៤-ឧបាសិកា	**តាំង**	**ឆៀវម៉ៅ**	នៅរដ្ឋកាលីហ្វ័រញ៉ា (USA)	ថវិកា	២៣.០០០	USD
៥-លោកស្រី	**សែម**	**ស្រី**	នៅរដ្ឋកាលីហ្វ័រញ៉ា (USA)	ថវិកា	២៤.០០០	USD
៦-ព្រះតេជគុណ	**ឆាន**	**ផន**	គ្រូសូត្រស្តាំវត្តព្រៃតុម្ព	ថវិកា	១២.៣០០	USD
៧-លោក	**សៅ**	**ម៉េង**		ថវិកា	១១.០៥០	USD

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ២៧១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

ស ំ រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ដែលបានបរិច្ចាគថវិកា ជួយកសាងសមិទ្ធផលផ្សេង ៗ ក្នុងវត្តអង្គរជ័យ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម ÷

ក - **មេដាយមាសស្ថាបនាជាតិ** :

១ - លោកអាចារ្យ **មាស សាមួន** ថវិកា ១១.២៥០ USD

២ - ព្រះតេជគុណ **ជា និត** ថវិកា ១០.៥១១ USD

៣ - ព្រះមុនីតាបស **រស់ លី** ថវិកា ១១.៨៧៥ USD

៤ - ឯកឧត្តម **ឆៀ ងាញ់** និងលោកជំទាវ **តៅ តៀន**
ថវិកា ១០.៣៦២ USD និង ៥.000.000 រៀល

៥ - លោក **ឃាំង សារិន** លោក **ហ៊ុន ហៀន** និង លោក **សន តៀង**
នៅសហរដ្ឋអាមេរិក ថវិកា ៣២.៤៧៦ USD

៦ - លោក **នុត សារឿន** អ្នកស្រី **សុខ ចន្ធី** ថវិកា ៣២.៤៧៦ USD

៧- លោក **កុង គីមហៀម** និងលោក **លឹម សំអាត** នៅសហរដ្ឋអាមេរិក ថវិកា ១៦.០៥៦ USD

៨- លោក **ឈិត ឈឿត** នៅសហរដ្ឋអាមេរិក ថវិកា ១៥.៦៧៨ USD

៩- លោក **ឡាំ ស៊ូរ៉េង** នៅសហរដ្ឋអាមេរិក ថវិកា ១៥.០៤៩ USD

១០- លោកគ្រូ **គង់ លន់** ថវិកា ១១.៨៧២ USD

១១- ឧបាសិកា **ឯម ណែស៊ា** ថវិកា ១១.២៣១ USD

ខ - **មេដាយប្រាក់ស្ថាបនាជាតិ** :

១ - លោក **ឯក សម្បត្តិ** ថវិកា ៨.២១៤ USD

២ - ឯកឧត្តម **អ៊ុំ ម៉ាន់រិទ្ធ** និង លោកជំទាវ **កែប សំ** ថវិកា ៥.២០០ USD

៣ - ឧត្តមសេនីយ៍ **ប៊ុល និត** និង លោកស្រី **ជា លាន** ថវិកា ៥.៨៧១ USD

គ - **មេដាយសំរិទ្ធស្ថាបនាជាតិ** :

១- ឯកឧត្តម **ខៀវ កាញារីទ្ធ** និងលោកជំទាវ **ឆេព ខឿ** ថវិកា ៣.៨២១ USD និង ២.៩៥០.០០០ រៀល

២- លោកជំទាវ **ហូ ណារូន** ថវិកា ២.៤១៦ USD

៣- ឯកឧត្តម **សុខ ជីវហាក់** និង លោកជំទាវ ថវិកា ២.១៥០ USD

៤- លោកតា **សុខ** ថវិកា ៣.១៧០ USD

៥- លោក **សុខ សារឿន** និង លោកស្រី **នួច ម៉ុម** ថវិកា ២.៤៨០ USD

៦- លោកស្រី **ស៊ុយ សុផាន** និងស្វាមី ថវិកា ២.៣៣០ USD

៧- លោកស្រី **ហេង ចន្ធី** និងក្រុមគ្រួសារ ថវិកា ២.៣៦៥ USD

៨- លោក **អ៊ុន ណែម** និងលោកស្រី **មាស កន** ថវិកា ២.១១៣ USD

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ